# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ពូអើយ បើសម្លាប់ខ្ញុំ ក៏សម្លាប់ទៅចុះ បើខ្ញុំនៅក៏គ្មានន័យអីទៀតដែរ គ្មានគោលដៅអីទេ*
*ខ្ញុំក្លាយជាកូនកំព្រាហើយ ហើយក៏ខ្ញុំអត់មានគោលដៅ គ្មានម៉ែ គ្មានឪណាជួយទំនុកបម្រុងខ្ញុំទេ។*
*ពូអើយសម្លាប់ខ្ញុំចុះ។*

- លោកស្រី អោ រី
ជាដើមបណ្តឹងរដ្ឋប្បវេណី

## I. ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះ បានបន្តស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក មាស សារ៉ាន់ ដែលជាគិលានុបដ្ឋាម្នាក់នៅអង្គភាពសង្គ្រោះបន្ទាន់អ្នករងរបួសក្នុងបុរីកីឡា មុនខ្មែរក្រហមវាយបែកភ្នំពេញ ហើយ គាត់បានព្រាត់ប្រាស់ប្រពន្ធរបស់គាត់ក្នុងពេលជម្លៀសចេញពីភ្នំពេញ។[1] ក្រោយពីបញ្ចប់សក្ខីកម្មរបស់គាត់ អង្គជំនុំជម្រះបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតគឺ អ្នកស្រី អោ រី ដែលគ្រួសាររបស់អ្នកស្រីបានជួបប្រទះការជម្លៀសដោយបង្ខំពីរដងគឺ ពីភ្នំពេញទៅភូមិកំណើតរបស់អ្នកស្រីក្នុងខេត្តកណ្តាល ហើយបន្ទាប់មកបន្តទៅខេត្តបាត់ដំបង។ ដើមបណ្តឹងរដ្ឋប្បវេណីទីបីគឺ លោក ចៅ នី បានធ្វើសក្ខីកម្មនៅថ្ងៃសុក្រ ហើយបានផ្តល់ព័ត៌មានសំខាន់ៗ ពីបទពិសោធន៍របស់គាត់ក្នុងនាមជាខ្មែរកម្ពុជាក្រោមម្នាក់ ក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

បញ្ហានីតិវិធីជាច្រើនត្រូវបានលើកឡើងមកពិភាក្សាដូចជា ការប្រើប្រាស់សំណួរដឹកមុខ ការដាក់ឯកសារយោងពីសំណាក់ក្រុមមេធាវីការពារក្តីលោក **នួន ជា** ទៅលើអត្ថបទសិក្សាស្រាវជ្រាវ សំណួរមិនជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចដំណើរការនីតិវិធី ហើយបញ្ហាតានតឹងជាងគេគឺ ថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សំណួរលើជនជាប់ចោទក្នុងកំឡុងពេលធ្វើសេចក្តីថ្លែងរៀបរាប់ពីទុក្ខសោកវេទនាបានឬទេ។ គួរឲចាប់អារម្មណ៍ជាងនេះទៅទៀតនោះគឺថា អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲមានការបញ្ចេញមតិផ្ទាល់ពីសំណាក់ជនជាប់ចោទ **ខៀវ សំផន** ដោយមិនចាំបាច់ឆ្លងកាត់មេធាវីរបស់គាត់ឡើយ ទោះបីជាមេធាវីការពារក្តីរបស់គាត់ កញ្ញា អាន់តា ហ្គីសសេ បានស្នើធ្វើបទដ្ឋានជំនួសកូនក្តីរបស់ខ្លួនយ៉ាងណាក៏ដោយ។

## II. សក្ខីកម្មសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណី លោក មាស សារ៉ាន់ ជាគិលានុបដ្ឋាកក្នុងស្ថាប័នសុខាភិបាលនៃរបបយោធា លន់ ណុល បានធ្វើសក្ខីកម្មពីបទពិសោធន៍របស់គាត់ក្នុងទីក្រុងភ្នំពេញមុនពេលកងកម្លាំងខ្មែរក្រហមវាយចូលមកដល់បន្តិច។ គាត់បាននិយាយលម្អិតពីបទពិសោធន៍ឈឺចាប់របស់គាត់ជុំវិញការជម្លៀសចេញពីទីក្រុង ការបោះបង់អ្នកជម្ងឺក្នុងមន្ទីរពេទ្យពេលគាត់ត្រូវជម្លៀសចេញ និង ការព្រាត់ប្រាស់ជាមួយប្រពន្ធរបស់គាត់។ ជាកិច្ចបន្ទាប់ ដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី អោ រី បានផ្ដល់សក្ខីកម្មទាក់ទងនឹងការជម្លៀសចេញពីភ្នំពេញ ហើយក្រោយមក ចេញពីខេត្តកណ្ដាលទៅកាន់ភាគពាយ័ព្យ។ លោក ចៅ នី ជាដើមបណ្ដឹងរដ្ឋប្បវេណីទីបី បានធ្វើសក្ខីកម្មក្នុងសប្ដាហ៍នេះ បានប្រាប់ពីស្ថានការណ៍គាបសង្កត់ជិះជាន់ក្រោយការជម្លៀសចេញពីភ្នំពេញ ដែលទីបំផុតឈានដល់ការស្លាប់បងប្រុសនិងក្មួយរបស់គាត់។

### ក. សក្ខីកម្ម មាស សារ៉ាន់

ក្នុងកិច្ចដំណើរការនីតិវិធីនាថ្ងៃព្រហស្បតិ៍ភាគច្រើន ដើមបណ្ដឹងរដ្ឋប្បវេណី លោក មាស សារ៉ាន់ (TCCP 82) បានធ្វើសក្ខីកម្មទៅលើបទពិសោធន៍របស់គាត់ក្នុងភ្នំពេញ ទាំងមុននិងក្រោយការជម្លៀសដោយបង្ខំនៅថ្ងៃ ១៧ មេសា ១៩៧៥។[2] គាត់បានរៀបរាប់ពីស្ថានការណ៍ ដែលលាតត្រដាងពីការងារពេទ្យរបស់គាត់ជាគិលានុបដ្ឋានៅផ្នែកសង្គ្រោះបន្ទាន់ក្នុងបុរីកីឡា ដែលគាត់ក៏បានហៅថាជា *"កន្លែងវះកាត់"*។ គាត់បានពន្យល់ថា គាត់បានព្រាត់ប្រាស់ពីប្រពន្ធរបស់គាត់ដោយសារតែការបង្ខំឲជម្លៀសភ្លាមៗ ហើយនិងភាពវឹកវរជាបន្តបន្ទាប់នៅតាមផ្លូវ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានលម្អិតពីការធ្វើដំណើររបស់គាត់ទៅកាន់ផ្ទះគ្រួសារប្រពន្ធរបស់គាត់នៅ ស៊ីសុផុន ជាកន្លែងដែលគាត់ស្វែងរកប្រពន្ធរបស់គាត់ ក៏ដូចជាការចាប់ខ្លួនរបស់គាត់ជាបន្តបន្ទាប់ ការសួរចម្លើយ និង ការធ្វើទារុណកម្មមកលើគាត់ រួមជាមួយនឹងប្រជាជន *"ថ្មី"* ផ្សេងទៀត។

#### ១. ភ្នំពេញ មុនពេល ១៧ មេសា ១៩៧៥

លោក មាស សារ៉ាន់ កើតនៅខេត្តស្វាយរៀង បានចាកចេញទៅភ្នំពេញនៅដើមឆ្នាំ១៩៦៩ ដើម្បីទៅរៀនពេទ្យ។ ក្រោយពីបញ្ចប់ការសិក្សាក្នុងឆ្នាំ១៩៧២ គាត់បានធ្វើការនៅមន្ទីរពេទ្យយោធាព្រះកេតុមេលានៅភ្នំពេញ។ នៅឆ្នាំ១៩៧៣ គាត់បានចូលទាហានប្រហែលជា១៨ខែ ហើយត្រូវបានបញ្ជូនទៅ ស៊ីសុផុន។ ក្រោយមក គាត់បានវិលត្រឡប់មកភ្នំពេញវិញនៅចុងឆ្នាំ១៩៧៤ មកធ្វើការជាគិលានុបដ្ឋាសង្គ្រោះបន្ទាន់នៅបុរីកីឡារហូតដល់ខ្មែរក្រហមវាយចូលភ្នំពេញនៅខែមេសា ១៩៧៥។

យោងតាមលោក មាស សារ៉ាន់ មនុស្សជាច្រើនបានចូលមកភ្នំពេញកាន់តែច្រើនឡើង ហើយរដ្ឋាភិបាលបានបង្កើតកន្លែងផ្សេងៗជាច្រើន ដើម្បីបំពេញកំនើននៃតម្រូវការសេវាកម្មសាធារណៈនេះ ដូចជាការបង្កើតមន្ទីរថ្មីមួយភ្លាមក្នុងតារាងបាល់បោះចាស់មួយនៅបុរីកីឡា ដែលជាកន្លែងគាត់ធ្វើការ។ ជាងនេះទៅទៀត ម្ហូបអាហារអីវ៉ាន់បានឡើងថ្លៃកប់ពពក ហើយពិបាករកទៀត។ ពេលគាត់នៅរៀនមហាវិទ្យាល័យនៅភ្នំពេញ មិនមានការខ្វះខាតអាហារទេ ប៉ុន្តែតម្លៃរបស់របរទូទៅបានកើនឡើងថេរមុនពេលគាត់ចាកចេញទៅស៊ីសុផុន ក្នុងឆ្នាំ ១៩៧២ ពេល *"មនុស្សវាកាន់តែច្រើន ... មិនមែនភ្នំពេញអត់អាហារទេ។"* ដើមបណ្ដឹង-រដ្ឋប្បវេណីបាននិយាយថាវត្តអារ៉ាមបានកកកុញទៅដោយជនភៀសខ្លួន ដោយសារតែខ្មែរក្រហមបានបុករុក

កាន់តែជិតភ្នំពេញ ហើយមានផ្ទះសម្បែងជាច្រើន បានក្លាយជាសំណាក់នៃគ្រួសារជនភៀសខ្លួនមួយចំនួន។ ផ្ទះប្រពន្ធគាត់បានទទួលសំណាក់៦ឬ៧គ្រួសារ។ ដើមបណ្តឹងរដ្ឋប្បវេណីបានប៉ាន់ប្រមាណថា ប្រជាជនក្នុងទីក្រុងភ្នំពេញបានកើនឡើង៣ដងត្រឹមខែមេសា ១៩៧៥ ដោយសារតែលំហូរចូលដ៏សន្ធឹកសន្ធាប់នេះ។

## ២. ការជម្លៀសចេញពីភ្នំពេញ

លោក មាស សារ៉ាន់ បានផ្តល់សក្ខីកម្មថា មានប្រជាជនកាន់តែច្រើនឡើង ត្រូវបានបញ្ជូនមកកាន់មន្ទីរវះកាត់បុរីកីឡា ដែលជាកន្លែងសម្រាប់ទទួលអ្នកជម្ងឺរងរបួសពីសមរភូមិនិងការទម្លាក់គ្រាប់បែកដោយឥតរសាយនៅមុនថ្ងៃឈានមកដល់ *"ការរំដោះ"* នៅថ្ងៃ ១៧ មេសា ១៩៧៥។ គាត់ចាំបានថា មន្ទីរសង្គ្រោះបន្ទាន់នេះ មានថ្នាំសង្កូវនិងវេជ្ជបណ្ឌិតគ្រប់គ្រាន់ ក៏ដូចជាជំនួយការពីសិក្ខាកាមមួយចំនួន ប៉ុន្តែផ្នែករបស់គាត់មានកង្វះខាតឧបករណ៍និងសម្ភារះពេទ្យ ដែលចាំបាច់សម្រាប់ព្យាបាលអ្នកត្រូវរបួស។

នៅល្ងាចថ្ងៃ ១៦ មេសា គ្រាប់បែកត្រូវបានទម្លាក់លើផ្សារឌុយមិចនៅភ្នំពេញ។ នៅមន្ទីរពេទ្យរបស់គាត់មានគ្រែត្រឹមតែ៥០ប៉ុណ្ណោះ មិនគ្រប់គ្រាន់សម្រាប់អ្នករងរបួសទាំងអស់ទេ ដូច្នេះអ្នកជំងឺខ្លះត្រូវបានដាក់ឲនៅសម្រាកលើកម្រាលឥដ្ឋ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកដល់ ក្មេងអាយុ៧ឆ្នាំម្នាក់ ដែលរងរបួសធ្ងន់ដោយសារគ្រាប់បែកៈ *"ហើយកូនហ្នឹងដែលៗនឹងដី ហើយខ្ញុំជំពាក់ភ្នែក ខ្ញុំជាប់ជំពាក់ខួរក្បាលខ្ញុំ ខ្ញុំឃើញវារហូត ដោយសារខ្ញុំអត់អាចជួយវាកើត នៅពេលដែលគេដេញចេញពីក្នុងមន្ទីរពេទ្យ។"*

លោក មាស សារ៉ាន់ បានពន្យល់ថា គាត់ត្រូវបានប្រាប់ឲចាកចេញពីបុរីកីឡានិងភ្នំពេញ ជាមួយនឹងអ្នកធ្វើការជាមួយគាត់និងអ្នកជម្ងឺនៅព្រឹកថ្ងៃ ១៧ មេសា ១៩៧៥។ បុគ្គលិកពេទ្យផ្សេងទៀតបានប្រាប់គាត់ថា ទាហានខ្មែរក្រហមបានព្រមានពីការទម្លាក់គ្រាប់បែកឆាប់ៗនេះ ហេតុដូច្នេះ គាត់ក៏មានការភ័យខ្លាចបន្តស្ថិតនៅក្នុងទីក្រុងទៀត។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា បានឃើញអ្នកជម្ងឺបាត់បង់សមត្ថភាពត្រូវបាន គេរុញចេញពីគ្រែ ហើយគាត់បានពន្យល់ពីប្រតិកម្មរបស់គាត់ជាលក្ខណៈផ្ទាល់ខ្លួន និងក្នុងនាមជាពេទ្យម្នាក់ ទាក់ទងនឹងការជម្លៀសចេញពីភ្នំពេញៈ

> *នៅពេលហ្នឹង ក្នុងចិត្តខ្ញុំថាតើខ្ញុំត្រូវធ្វើម៉េច ដែលគេថាឲចេញ។ ក៏ប៉ុន្តែខ្ញុំមានចិត្តនឹកក្នុងចិត្តមួយដែរថាប្រហែលជា អ្នកដែលដេញហ្នឹងទទួលមើលអ្នកជម្ងឺ ពីព្រោះជាអ្នករបួស ជាអ្នកដែលត្រូវគ្រាប់ ប្រហែលជាគេជួយ។ ខ្ញុំមិនអស់ចិត្តអំពីរឿងកូនស្រីមួយដែលវាធ្លាយពោះហ្នឹង ដែលវាចាប់អាវខ្ញុំ វាថាឲខ្ញុំសូមទៅជាមួយយកខ្ញុំទៅផង។ ហើយខ្ញុំយកទៅឯណា ក្នុងពេលនុំងមនុស្សភ័យ សុទ្ធតែរត់។*

ព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ វ៉ាយដ៍ ដេស្មាឯល បានសួរដើមបណ្តឹងរដ្ឋប្បវេណីឲឆ្លើយ តបទៅនឹងសេចក្តីថ្លែងការណ៍របស់ **នួន ជា** ដែលបង្ហាញពីភាពសមហេតុសមផលក្នុងការធ្វើការជម្លៀសចេញពីទីក្រុងនិងអ្នកជម្ងឺ ដោយហេតុផលថា វាជាការចាំបាច់ដោយសារតែសង្គ្រាមនាពេលនោះ។[3] លោក មាស សារ៉ាន់ បានឆ្លើយតបថាមិនមានទាហានខ្មែរក្រហមឬគិលានុបដ្ឋាណា បានមកជួយដឹកអ្នករបួសចេញពីទីក្រុងទេ។ គាត់ត្រូវបានប្រាប់ថា គាត់នឹងអាចវិលត្រលប់មកភ្នំពេញក្នុងរយៈពេល២ឬ៣ថ្ងៃបន្ទាប់ ហើយមិនចាំបាច់យករបស់របរតាមជាប់ខ្លួនច្រើនពេកទេ។ គាត់មិនត្រូវបានអនុញ្ញាតិឲទៅផ្ទះមួយនៅផ្លូវប៉ាស្ទ័រ ដែលប្រពន្ធគាត់ស្នាក់នៅនាពេលនោះ ពីព្រោះ វាមានការបាញ់បោះនៅតាមផ្លូវទៅទីនោះ។ គាត់បានសំដៅទៅខាងត្បូងវិញ

ទៅផ្ទះជួលរបស់ពួកគាត់ ហើយយកថ្នាំអាស្ពៀរិនមួនដប អាវយឺតប្រពន្ធគាត់មួយ និងខ្សែកប្រពន្ធគាត់មួយខ្សែ។ លោក មាស សារ៉ាន់ បាននិយាយថា គាត់មិនដែលបានដំណឹងប្រពន្ធគាត់ម្តងទៀតទេ៖ *"តាំងតែពីពេលនុំង ជនកម្សត់ហ្នឹងគ្មាន ខ្ញុំគ្មានបានដំណឹង ខ្ញុំគ្មានបានដំណឹងពី៧៩ រហូតមកដល់ឲឡូវ រហូតមកដល់ខ្ញុំអង្គុយ ខ្ញុំអត់មានដឹងថាគាត់ៗយ៉ាងម៉េចទេ ប៉ុន្តែវាមិនអាច ឧបមាថាមនុស្សហ្នឹងវាលូនក៏ដល់ផ្ទះដែរ ខ្ញុំពុំដឹង ប៉ុន្តែខ្ញុំអត់ដឹង អត់មានដឹង អត់មានព័ត៌មានអីទាំងអស់។"*

### ៣. ការចាកចេញពីភ្នំពេញ និង ការមកដល់ស៊ីសុផន

ក្នុងខណៈគាត់កំពុងចាកចេញពីទីក្រុង លោក មាស សារ៉ាន់ បានឃើញសាកសពបុរស២នាក់ស្លៀកពាក់ជាស៊ីវិលនៅស្ពានមុន្នីវង្ស ប៉ុន្តែគាត់មិនដឹងថាពួកគេស្លាប់ដោយរបៀបណាទេ។ វាធ្វើឲគាត់មានការតក់ស្លុតដូចជាការគំរាមថានឹងមានគ្រាប់បែកធ្លាក់។ គាត់ត្រូវបានគេប្រាប់ថា អ្នកទីក្រុងនឹងអាចត្រលប់មកវិញនៅ៣ថ្ងៃក្រោយ ប៉ុន្តែដោយបានឃើញមានប្រជាជនទាំងហ្វូងៗ ធ្វើដំណើរចាកចេញ គាត់បានគិតថា វាមិនអាចទៅរួចទេ ដូច្នេះគាត់បានជ្រើសរើសនៅបន្តជុំវិញស្ពានមុន្នីវង្សជាមួយអ្នកជម្លៀសផ្សេងទៀត ជាជាងធ្វើដំណើរបន្តទៅស្រុកកំណើតរបស់គាត់នៅខេត្តស្វាយរៀង។ លោក មាស សារ៉ាន់ បានព្រួយបារម្ភណ៍កាន់តែខ្លាំងឡើង ពេលដែលគាត់បានចាំប្រពន្ធរបស់គាត់អស់រយៈពេល៣ថ្ងៃនៅស្ពានមុន្នីវង្ស ហើយនៅតែមិនបានឃើញប្រពន្ធរបស់គាត់ឆ្លងកាត់ទាល់តែសោះ ហើយប្រពន្ធគាត់បានកំពុងមាន *"ពោះធំ ហើយមិនដែលស្គាល់ភ្នំពេញ។"* នៅថ្ងៃទី៣ បន្ទាប់ពីការជម្លៀស លោក មាស សារ៉ាន់ បានឮសេចក្តីប្រកាសតាមឧឃោសនស័ព្ទឲអតីតអ្នករដ្ឋការនិង ទាហានត្រលប់មកធ្វើការភ្នំពេញវិញ ប៉ុន្តែ *"អ្នកដែលទៅហ្នឹងគេទៅៗតែម្នាក់ឯង អត់មានគ្រួសារទៅ ហើយ មិនឃើញមានត្រឡប់មកវិញសោះ។"* ដោយខ្លាចសាកសពដែលគាត់បានឃើញនៅស្ពាន ហើយមិនចង់ប្រថុយប្រថានត្រឡប់ទៅភ្នំពេញវិញ គាត់បានសម្រេចចិត្តទៅរកមើលប្រពន្ធគាត់នៅភូមិប្រពន្ធរបស់គាត់នៅ ស៊ីសុផន។

លោក មាស សារ៉ាន់ និង អ្នកជម្លៀសផ្សេងទៀតបានយកមាសដូរយកម៉ូតូនិងសាឡាងជិះឆ្លងកាត់ទន្លេទៅក្រោយម្ខាងទៀតនៃស្ពានជ្រោយចង្វា។ ពួកគាត់បានជួបអ្នកធ្វើដំណើរផ្សេងទៀតតាមផ្លូវជាតិលេខ៦ និងបានឃើញទាហានខ្មែរក្រហមខ្លះៗនៅក្នុងឡានកាមីញ៉ុង ប៉ុន្តែពួកគាត់មិនត្រូវបានបញ្ឈប់ទេ រហូតមកដល់ប៉ុស្តិ៍ត្រួតពិនិត្យមួយនៅបាធាយក្នុងខេត្តកំពង់ចាម។ នៅទីនោះ ពួកគាត់ត្រូវបានគេសួរម្តងម្នាក់ៗ ហើយអាគុយម៉ូតូរបស់គាត់ត្រូវបានគេរឹបអូសសម្រាប់សាកវិទ្យុរបស់ទាហាន។ ដើមបណ្តឹងរដ្ឋប្បវេណីបានយកម៉ូតូមកវិញ ហើយឆ្នៃទៅជារទេះរុញសម្រាប់ដឹកស្ករនិងអង្កររបស់ក្រុមជម្លៀស។ ពួកគេបានប្រើប្រាស់គ្រឿងផ្គត់ផ្គង់ទាំងនេះ ជាមួយនឹងសាំងម៉ូតូនិងថ្នាំអាស្ពីរីនដើម្បីប្តូរយកម្ហូបអាហារបន្ថែមនៅតាមផ្លូវ។

ក្រុមរួមដំណើររបស់គាត់បានជួបប្រទះគ្រោះថ្នាក់នៅវាល់ប៉ុស្តិ៍ត្រួតពិនិត្យ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា *"អ្នកដែលទៅគេសួរហ្នឹងៗ វាបាត់មនុស្សហ្នឹងដង្ហែតាំងតែពីផុតពីផ្សារទៅហ្នឹងរហូតទៅដល់ស៊ីសុផុន។"* លោក មាស សារ៉ាន់ បានរួចផុតពីសេចក្តីស្លាប់នៅវាល់ប៉ុស្តិ៍ត្រួតពិនិត្យ ដោយការកុហកលាក់បាំងពីអត្តសញ្ញាណរបស់គាត់ថា៖

> *គឺថាខ្ញុំករ ខ្ញុំថាខ្ញុំបើកតាក់ស៊ី ... ខ្ញុំប្រាប់ទៅគេ ភូមិខ្ញុំនៅខាងមុខជិតដល់។ ខ្ញុំបានទៅ ក៏ប៉ុន្តែក្នុងចំណោមអ្នកដែលទៅជាមួយហ្នឹង ដែលដើរជាមួយគ្នាហ្នឹង ហើយគេយកចេញទៅក្រៅ ... វាបាត់គេយកចេញទៅ ខ្ញុំមិនដឹងជាគេយក*

*ទៅណា។ ហើយការចេញ ជួបអ៊ីចឹងរហូតគ្រាតែខ្ញុំទៅដល់ស្រុកប្រពន្ធខ្ញុំបាទ។ ... ខ្ញុំអត់មានទុកចិត្ត នៅពេលដែលគេហៅមនុស្សចូលទៅក្នុងភ្នំពេញវិញ ហើយបាត់ៗ ហើយរឿង៣ថ្ងៃដែលថា "ទម្លាក់គ្រាប់បែក" វាអត់មាន។ ... បានខ្ញុំសម្រេចថាភរ។*

ពេលមកដល់ភូមិកំណើតប្រពន្ធគាត់ គាត់មិនបានឃើញប្រពន្ធគាត់ទេ ហើយម្ដាយក្មេកគាត់បានយំពីព្រោះប្រពន្ធគាត់មិនបានមកជាមួយគាត់។ ម្ដាយក្មេកគាត់បានប្រាប់គាត់ថា *"អង្គការវ៉ៃកូនដូចម្ចាស់ ហើយឲខ្ញុំទៅប្រាប់គេតាមត្រង់។"* គាត់ក៏ធ្វើតាមដំបូន្មាននេះ ហើយប្រាប់ខ្មែរក្រហមថា គាត់ធ្វើពេទ្យ នៅមន្ទីរពេទ្យយោធា ហើយកំពុងតែរកប្រពន្ធនៅក្នុងភូមិមួយនេះ។ ៣ថ្ងៃក្រោយមកប្រហែលជាម៉ោង១០យប់ ប្រធានភូមិបានឲគាត់ទៅពិនិត្យមើលថ្នាំមកពីចិនថ្មីៗ។ ទោះបីជាគាត់មានមន្ទិលសង្ស័យបារម្ភពីការកោះហៅទាំងយប់ដូច្នេះក៏ដោយ គាត់បានទៅតាមប្រធានភូមិនៅឯចុងភូមិ។ គាត់ក៏ត្រូវបានគេចាប់ចង និងឃាត់ខ្លួននៅទីនោះ។ ដោយសំណាងល្អ សិស្សានុសិស្សក្នុងភូមិបានសុំមិនឲសម្លាប់គាត់ ប៉ុន្តែបញ្ជូនគាត់ទៅអប់រំកែប្រែជំនួសវិញ។ អ្នកទោសទាំងអស់ត្រូវបានដាក់ក្នុងបន្ទប់សិក្សាមួយនៃមន្ទីរឃុំឃាំងនៅអតីតវិទ្យាល័យស៊ីសុផន។ នៅថ្ងៃទី៣ គាត់ត្រូវបានកោះហៅសួរចម្លើយនិងធ្វើទារុណកម្ម។ ក្រោយមកបន្តិច គាត់ក៏ត្រូវបានបញ្ជូនទៅបន្ទប់មួយផ្សេងទៀតសម្រាប់ការអប់រំកែប្រែ ដែលជាកន្លែងពួកគេពិភាក្សាគ្នាពី *"អ្នកមាន អ្នកក្រហ្មឹង ... រួចហើយក៏ចាប់និយាយអំពីបដិវត្តន៍នៅស្រុកបារាំងនៅឆ្នាំ១៨៨៩។"* លោក មាស សារ៉ាន់ មានការភ្ញាក់ផ្អើល ពេលគាត់ត្រូវបានដោះលែងពីការឃុំឃាំង ហើយអនុញ្ញាតិឲត្រឡប់មកភូមិប្រពន្ធគាត់វិញ។

ពេលមកភូមិវិញ មិនមានអ្នកណាម្នាក់មកលែងសួរនាំគាត់ទៀតទេ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា អ្នកភូមិ *"ខ្លាច"* ដោយសារតែមានពាក្យចចាមអារ៉ាមពីការស្លាប់របស់គាត់។ លោក មាស សារ៉ាន់ បាននិយាយថា គាត់មិនត្រូវបានអនុញ្ញាតិឲផ្លាស់ទីតាមចិត្តទៀតទេ។ គាត់ត្រូវបានចាត់តាំងឲមើលទា ហើយជីកប្រឡាយនៅជិតភូមិ។ គាត់ចងចាំបានថា មានពេលមួយ បុរសម្នាក់ដែលមានទំនាក់ទនងជាមួយនារីម្នាក់ត្រូវបានគេចាប់ខ្លួននិងសម្លាប់នៅចំពោះកិច្ចប្រជុំថ្ងៃរសៀលជាប្រចាំ។ នៅក្នុងកិច្ចប្រជុំ អ្នកភូមិត្រូវបានប្រាប់ពីសមិទ្ធិផលស្រូវអង្ករនិងកូតាស្រូវក្នុងមួយហិកតា ហើយគាត់ត្រូវសម្តែងភាពស្មោះត្រង់របស់គាត់ឲជាប់លាប់ ហើយនិយាយដោយដើងធាក់ដីដៃឡើងលើថា *"បរាជ័យអាមេរិកាំង។"*

## ៤. សេចក្តីថ្លែងរៀបរាប់ពីទុក្ខសោកវេទនា ឥរិយាបថ និង ភាពគួរឲជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងសេចក្តីថ្លែងរៀបរាប់ពីទុក្ខសោកវេទនា លោក មាស សារ៉ាន់ បានរ៉ាយរ៉ាប់ម្តងទៀតពីការបាត់បង់ជីវិតរបស់ប្រពន្ធគាត់និងសមាជិកគ្រួសារផ្សេងទៀត។ យ៉ាងណាក៏ដោយ គាត់បានផ្តោតសេចក្តីថ្លែងការណ៍នេះ ទៅលើសំណើពិសេសមួយមិនធ្លាប់មានពីមុនមក ដោយស្នើសុំឲបូជាគ្រោងឆ្អឹង ដែលនៅសល់ទាំងអស់របស់ជនរងគ្រោះ ដែលដាក់បង្ហាញសព្វថ្ងៃនេះ នៅតាមបណ្តាកន្លែងរំលឹកវិញ្ញាណខ័ន្ធ ឬកន្លែងរំលឹកប្រវត្តិសាស្ត្រនានា។ ដោយយល់ថាឆ្អឹងទាំងនោះអាចរាប់បញ្ចូលឆ្អឹងរបស់ប្រពន្ធគាត់ ដើមបណ្តឹង-រដ្ឋប្បវេណី បានទទូចឲអង្គជំនុំជម្រះបូជាឆ្អឹងនៅសល់ទាំងអស់តាមប្រពៃណីខ្មែរ ហើយ រក្សាទុកធាតុទាំងអស់នៅក្នុង ចេតិយមួយជានិមិត្តសញ្ញានៃអតីតកាល។ គាត់បានបញ្ចប់សក្ខីកម្មរបស់គាត់ ជាមួយនឹង

អារម្មណ៍រំជួលចិត្តពីការបាត់បង់ភរិយារបស់គាត់ ដោយលើកដៃសំពះបង្ហាញពីសេចក្តីគោរព និង សេចក្តីស្រលាញ់ចំពោះប្រពន្ធរបស់គាត់។ គាត់បាននិយាយថា៖

> *ខ្ញុំបាត់ប្រពន្ធខ្ញុំរហូតមកដល់ពេលនេះ ខ្ញុំមិនដឹងនៅឯណាផង។ ខ្ញុំមិនដឹងកូនខ្ញុំរស់ឬស្លាប់ផង។ ... ចេតិយមួយ ... ឲគេមើលឃើញគ្រប់គ្នា ... ឲមនុស្សហ្នឹង ដឹ ថា នេះជារឿងកុំឲកើតមានថ្ងៃក្រោយ។*

ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយតបភ្លាមៗ ស្ទើរតែគ្រប់សំណួរ។ លោក មាស សារ៉ាន់ មិនមានបញ្ហាក្នុងការយល់សំណួរដែលបានសួរគាត់ទេ។

## ខ. **សក្ខីកម្ម អោ រី**

ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អោ រី (TCCP 105) បានចាប់ផ្តើមធ្វើសក្ខីកម្មនៅថ្ងៃព្រហស្បតិ៍ និងបន្តដល់ព្រឹកថ្ងៃសុក្រ[4] គាត់បានរស់នៅភ្នំពេញក្នុងរបបលន់ណុល។ លោកស្រីនិងគ្រួសារត្រូវបានជម្លៀសទៅភូមិត្បូងដំរី និងបន្ទាប់មកទៅភូមិចម្ការតាពូ ខេត្តពោធិ៍សាត់ ក្នុងកំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។

### ១. **ការមកដល់នៃខ្មែរក្រហម ក្នុងភ្នំពេញ**

នៅប៉ុន្មានខែមុនពេលភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អោ រី បាននិយាយថា *"គ្រាប់ផ្លោង"* បានទម្លាក់ចូលភ្នំពេញ បង្ករបួសនិងសម្លាប់អ្នកជិតខាងគាត់។ ក្នុងខណៈមួយគ្រាប់បែកផ្លោងចំផ្ទះពួកគាត់ ហើយបណ្តាលឲបងស្រីគាត់របួសជាទម្ងន់។ លោកស្រីបាននិយាយថា ពេលពួកគាត់បានយកបងស្រីទៅពេទ្យធំ ពួកគាត់ត្រូវតែសូកប៉ាន់គ្រូពេទ្យដើម្បីទទួលបានសេវាកម្មព្យាបាល។ បីថ្ងៃបន្ទាប់ពីបងស្រីរបស់គាត់ចេញពីមន្ទីរពេទ្យ ខ្មែរក្រហមបានចូលមកដល់ភ្នំពេញ។ នាពេលនោះ ទាហានខ្មែរក្រហមបានប្រកាសថាប្រជាជនទាំងអស់ត្រូវតែចាកចេញភ្នំពេញរយៈពេល៣ថ្ងៃ ដោយមិន បានប្រាប់ពីហេតុផលទេ។ ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា *"មានកាំភ្លើង កាណុងកាំភ្លើង ដើរកៀស ប្រជាជនឲចេញ។"* ដូច្នេះ ពួកគាត់បានចាកចេញ ហើយសំដៅទៅ ភូមិត្បូងដំរី[5] ដែលជាភូមិយាយលោកស្រី។ លោកស្រី អោ រី បាននិយាយថា គ្រួសារលោកស្រីមានការស្ទាក់ស្ទើរក្នុងការចាកចេញ ដោយស្តាយទ្រព្យសម្បត្តិនៅភ្នំពេញ ហើយ ម្តាយរបស់គាត់ទើបបង្កើតកូន និង បងស្រីនៅតែកំពុងព្យាបាលជម្ងឺ។

ពួកគេត្រូវបានប្រាប់ថា *"មិនបាច់យកទៅទេ។ មាន តាមផ្លូវមានហូបហើយ ឲតែមានលុយ មានរបស់របរហូបទាំងអស់ហើយ"* ដូច្នេះពួកគាត់មិនបានយកអ្វីទាំងអស់មានតែលុយ។ យ៉ាងណាមិញ នៅតាមផ្លូវពេលដែលពួកគាត់ត្រូវបានប្រាប់ថា គេលែងទទួលលុយកាក់ទៀតហើយ ម្តាយលោកស្រីបានកើតក្តីព្រួយបារម្មណ៍យ៉ាងខ្លាំង ដោយសារ គាត់មិនអាចទិញអ្វីៗបានឲកូនចៅគាត់ហូបទៀតទេ ហើយលោកស្រី និងបងប្អូនរបស់គាត់បានស្រែកយំឃ្លានបាយ។ លោកស្រី អោ រី បាននិយាយថា៖

> *ក្រុមគ្រួសារគេក៏ដូចតែក្រុមគ្រួសារខ្ញុំដែរ ដូចតែគ្នា អត់មានខុសគ្នាឡើយទេ។ មើលទៅ ម្នាក់ៗឲតែមានកូន គឺស្រែកយំដូចតែគ្នា កូនវាឃ្លានដែលមានលុយ*

*ហើយ មិនទិញគេ ទិញគេមិនបានស៊ី។ ម្ល៉ោះហើយ ឪពុកម្តាយខ្ញុំស្លុតត្រង់នុំង ហើយស្លុត។*

## ២. ភូមិត្បូងដំរី

ដោយយោងតាម លោកស្រី អោ រី នៅភូមិត្បូងដំរី លោកស្រីនិងគ្រួសារត្រូវបានគេចាត់ទុកថាជា *"អ្នកមូលដ្ឋានថ្មី"* ឬ *"អ្នកចំណូលថ្មី"* ហើយពួកគាត់មិនបានអនុញ្ញាតិឲ *"នៅជិតអ្នកមូលដ្ឋានចាស់ទេ។"* ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា លោកស្រីនៅក្មេងពេក មិនអាចយល់សាច់ការបាន ពេលដែលមានការបែងចែកបែបនេះ ប៉ុន្តែលោកស្រីបានឮថា *"អ្នកចំណូលថ្មី"* ត្រូវតែចុះឈ្មោះខ្លួនឯងជាមួយមេកង។ នៅត្បូងដំរី ម្តាយលោកស្រី អោ រី និងបងស្រីៗ ត្រូវបានគេចាត់ឲដេញសត្វចាបចេញពីវាលស្រែ។ ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយថា ស្បៀងអាហារនៅត្បូងដំរី មិនគ្រប់គ្រាន់ទេ។ ពួកគាត់បរិភោគជាសមូហភាព ហើយមេកងឲចំណែកគ្រួសារគាត់ ដំបូង៣វែក ដល់ក្រោយមកតែមួយវែកទេសម្រាប់ម្នាក់ៗ។

គ្រួសារដើមបណ្តឹងរដ្ឋប្បវេណី និង *"អ្នកចំណូលថ្មី"* ផ្សេងទៀតបានស្នាក់នៅត្បូងដំរីបានមួយរយៈ *"ទៅដល់ស្រុកកំណើតហើយ អង្គការហ្នឹងបញ្ជូនក្រុមគ្រួសារខ្ញុំទៅទៀត។"* ពួកគាត់ដើរទៅព្រែកតាមាក់ ដែលមានទាហានឈរយាមកាមនៅមាត់ទន្លេ ហើយមានកប៉ាល់ *"ច្រើនដែរ"* មកចាំទទួលពួកគាត់។ លោកស្រី អោ រី បាននិយាយថា កប៉ាល់ដែលគាត់ឡើងជិះ *"បិទប៉ាំ៉ាតង់ជិតអស់រលីង"* មើលមិនឃើញ ហើយមានអ្នកយាមពីមុខពីក្រោយ។ កប៉ាល់ដឹក *"អ្នកចំណូលថ្មី"* ទៅព្រែកព្នៅ ដែលនៅទីនោះ មានទាហានបំពាក់ដោយអាវុធ និង មេកង *"ស្លៀកពាក់ខោខ្មៅ អាវខ្មៅ ស្បែកជើងកង់ឡាន"* បានបង្គាប់ពួកគាត់ឲឡើង *"ឡានទ្រុង"* ដែលដឹកពួកគាត់ទៅពោធិ៍សាត់។ ដោយមិនបានធ្វើ ការប៉ាន់ស្មានចំនួន ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា មានឡានធំៗ និង មនុស្សអ៊ូអរជាច្រើន *"កប៉ាល់មកម្តងមួយៗមកចត។ ឡានទយដាក់ក្តិតឡើងព្រូៗ។"* ក្នុងពេលនោះ គេចែកនំប៉័ង ប៉ុន្តែលោកស្រី អោ រី ប្រាប់ថាវាមិនគ្រប់គ្រាន់។

## ៣. ភូមិចម្ការតាប៉ូ

លោកស្រី អោ រី បាននិយាយថា គ្រួសារលោកស្រី បានធ្វើដំណើរអស់មួយថ្ងៃពេញដើម្បីទៅដល់ខេត្តពោធិ៍សាត់ ហើយត្រូវបានដឹកយកបន្តទៅតាមរទេះគោទៅភូមិចម្ការតាពូ។ បន្ទាប់ពី៤ឬ៥ថ្ងៃ ក្នុងភូមិសមាជិកគ្រួសារត្រូវបានបំបែកចេញពីគ្នា។ លោកស្រី អោ រី បាននិយាយថា *"គេបែងចែកអស់ហើយ បងដោយបង ប្អូនដោយប្អូន ឪពុកដោយឪពុក ម្តាយដោយម្តាយ ... ទៅធ្វើការរៀងខ្លួន ... មានគេធ្វើផ្ទះទុកឲរួចស្រេច ផ្ទះល្វែងគេកាន់ខណ្ឌមួយបន្ទប់ៗ។"* ប្រជាជនមូលដ្ឋាន *"ចាស់"* និង *"ថ្មី"* បរិភោគរួមគ្នានៅសាលហូបបាយទោះបីជាពួកគាត់រស់នៅផ្សេងគ្នាក៏ដោយ។

ដើមបណ្តឹងរដ្ឋប្បវេណី បាននឹកឃើញពីស្ថានភាពលំបាកលំបិនរបស់គ្រួសារលោកស្រី ដែលបានជួបប្រទះនៅពោធិ៍សាត់។ លោកស្រី អោ រី ត្រូវបានចាត់តាំងឲកាប់ឈើធ្វើជីនិងដាំដើមដំឡូង។ លោកស្រីបានរំឭកថា គាត់មិនអាចធ្វើការបានស្រួលបួលទេ និង ត្រូវបានគេ *"វ៉ៃក្បាលខ្ញុំមួយភ្លូកចប ឡើងប្រកាច់ពេញកន្លែងទាំងអស់។ ប៉ុន្តែសំណាងខ្ញុំវាមិនងាប់ មួយស្របក់ខ្ញុំដឹងខ្លួនវិញទៅ។"* ម្តាយរបស់លោកស្រីត្រូវបានគេចាត់តាំងឲរែងអង្ករ និង ក្រោយមកធ្លាក់ខ្លួនឈឺដោយសារធ្វើការហួសកំណត់និងអស់កម្លាំងល្វិតល្វៃ។ លោកស្រីក៏បាននិយាយថាដែរថា លោកស្រីមិនត្រូវបានអនុញ្ញាតិឲជួយម្តាយទេ៖

*អត់ទេ គេមិនអនុញ្ញាតឲខ្ញុំមកទេ ប៉ុន្តែខ្ញុំអាណិតម្តាយពេក ខ្ញុំលួចរត់មក ព្រោះខ្ញុំ ថាបើគេទាន់ត្រង់ណា គេសម្លាប់ចោលត្រង់នុំង ក៏ខ្ញុំអស់ចិត្តដែរ។ ខ្ញុំមកលួចមក ទាំងយប់ មកដល់ម្តាយ ម្តាយយំស្រែក ថាកូនអើយ! បើគេទាន់គេវ៉ៃកូនឯង ងាប់ហើយ។ ប៉ុន្តែម៉ាក់ឯងកុំមាត់! បើគេវ៉ៃខ្ញុំក៏វ៉ៃទៅចុះ។*

យោងតាមលោកស្រី អោ រី ពេលដែលម្តាយលោកស្រីនិយាយថា គាត់ចង់ឃើញកូនចៅរបស់គាត់ គាត់ក៏ត្រូវគេបានឃុំខ្លួនមួយសប្តាហ៍ដោយឥតអាហារ។ លោកស្រី អោ រី និយាយថា ទាក់ទងនឹងរបបអាហារ ពេលដែលពួកគាត់មកដល់ពោធិ៍សាត់ ពួកគាត់បានដាំបាយសម្រាប់ថ្ងៃត្រង់ និង បបរសម្រាប់ពេលល្ងាយ។ ២ឬ៣ថ្ងៃក្រោយមក ពួកគាត់ទទួលបានតែបបររាវៗ មួយវែកលលាដ៍ដូង សម្រាប់អាហារមួយពេលប៉ុណ្ណោះ។ តាមការបកស្រាយរបស់ លោកស្រី អោ រី អាហារមានមិនគ្រប់គ្រាន់ទេ ហើយប្រជាជនមួយចំនួន បានស្លាប់ដោយសារការស្រេកឃ្លាន។ ជាងនេះទៅទៀត *"គ្រាប់អាចម៍ទន្សាយ"* ដែលផ្តល់ឲអ្នកឈឺ មិនបានជួយពួកគេទាល់តែសោះ។

ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ពីរបៀបដែលគ្រួសារលោកស្រីត្រូវបានគេសម្លាប់ក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ។ លោកស្រីបាននិយាយថា ប្អូនប្រុសរបស់លោកស្រីត្រូវបានគេចាប់ខ្លួននិងសម្លាប់ បន្ទាប់ពី គាត់ត្រូវបានខ្មែរក្រហមប្រទះឃើញឡើងដើមត្នោតយក *"ទឹកត្នោត"* ឲប្រពន្ធរបស់គាត់។ ក្រោយមក ក្នុងឆ្នាំ១៩៧៨ *"ពួកខ្មែរក្រហម"* បានសម្លាប់គ្រួសារលោកស្រី ហើយមានតែលោកស្រីនិងប្អូនប្រុស លោកស្រីបាននៅរស់ដល់សព្វថ្ងៃ។ កាលនោះ លោកស្រី អោ រី ទើបតែមានអាយុ១០ឆ្នាំជាង។ លោកស្រី និយាយថា លោកស្រីមិនបានដឹងពីមូលហេតុនៃការសម្លាប់នេះទេ។ លោកស្រីនិយាយថា គ្រួសារលោកស្រី និងអ្នកភូមិទាំងអស់ត្រូវបានបង្គាប់ឲចាកចេញពីផ្ទះរបស់ពួកគេ ពីព្រោះ វៀតណាមកំពុងតែវាយលុកចូល ហើយ ក្នុងកំឡុងពេលគ្រួសារគាត់បានកំពុងដេកក្នុងវាលស្រែនៅយប់មួយ ខ្មែរក្រហមបានមកបាញ់ពួកគាត់ ទាំងអស់។

*ក្រុមគ្រួសារខ្ញុំទាំងអស់ មួយពូជស្លាប់មួយថ្លុក នៅសល់តែខ្ញុំមួយ និងប្អូនប្រុស មួយលើកដៃសំពះអង្វរគេ ពូអើយកុំសម្លាប់ម្តាយខ្ញុំអី។ គេមិនអនុគ្រោះទេ ... គេដេញខ្ញុំថយចេញពីថ្លុកឈាមម្តាយខ្ញុំបានប្រហែលជា២០ម៉ែត្រ ខ្ញុំឮប្អូនខ្ញុំ ស្រែកយំ អាតូចនៅបៅដោះឮស្រែកយំ ខ្ញុំស្ទុះត្រឡប់ទៅវិញៗ ... គាត់បោះឡើង ទៅលើចាក់នឹងជំពុះទង់នៅនឹងមុខខ្ញុំ។*

លោកស្រី អោ រី បាននិយាយថា ពួកខ្មែរក្រហមព្យាយាមសម្លាប់លោកស្រីផងដែរ។ លោកស្រីបាន ព្យាយាមការពារគ្រួសារអ្នកស្រីដោយរងជំនួសពួកគាត់ ប៉ុន្តែពួកគាត់នៅតែស្លាប់។ *"ខ្ញុំថា សុខចិត្តឲចំខ្ញុំចុះ កុំឲចំម្តាយខ្ញុំ។ ខ្ញុំអត់ដឹងមូលហេតុអី បានជាមិនចំខ្ញុំ។"* លោកស្រីត្រូវរបួស តែមិនស្លាប់ទេ ដោយសំណាង់ល្អ គ្រាប់កាំភ្លើងបាញ់ត្រូវចំគូថទៅវិញ។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ក្រោយមក (ដោយមិនបានបញ្ជាក់ឲច្បាស់ ចាប់ពីពេលដែលគ្រួសារគាត់ត្រូវតែស្លាប់) ខ្មែរក្រហមបានប្រទះឃើញ លោកស្រី អោ រី និងប្អូនៗលោកស្រី ហើយប្រាប់ពួកគាត់ថា ពួកគាត់ត្រូវតែស្លាប់។ លោកស្រី អោ រី បានរៀបរាប់ហេតុការណ៍ដូចខាងក្រោម៖

*ពួកវាដើរមក ខ្ញុំយកក្រម៉ាគ្របមុខពីនាក់បងប្អូនឱបគ្នាជាប់លើកដៃថា "ពូអើយ បើសម្លាប់ខ្ញុំ ក៏សម្លាប់ទៅចុះ បើខ្ញុំនៅក៏គ្មានន័យអីទៀតដែរ គ្មានគោលដៅអីទេ ខ្ញុំក្លាយជាកូនកំព្រាហើយ ហើយក៏ខ្ញុំអត់មានគោលដៅ គ្មានម៉ែ គ្មានឪណាជួយ ទំនុកបម្រុងខ្ញុំទេ។ ពូអើយសម្លាប់ខ្ញុំចុះ។" វាយកកាំភ្លើងមកក្ដុងគុម្ពុត្រចៀកខ្ញុំ ពីរនាក់បងប្អូនឱបគ្នាឡើងញ័រអស់ហើយ នឹកថាស្លាប់ទាំង ពីរនាក់ ទវាដាច់ ពូជទៅ។*

លោកស្រីនិងប្អូនៗត្រូវបានដោះលែងផុតពីការសម្លាប់។ ប៉ុន្តែដូចដែលលោកស្រីបានបញ្ជាក់ក្នុងសក្ខីកម្មខាងលើមក ពួកគាត់រស់នៅយ៉ាងវេទនាក្រោយមក។ លោកស្រីបាននឹកឃើញពីសេចក្ដីលំបាកវេទនាមួយ ពេលប្អូនៗលោកស្រីស្រេកឃ្លានខ្លាំងពេក ហើយបានសុំអង្ករពីខ្មែរក្រហម ប៉ុន្តែមិនបានអ្វីទាំងអស់ បានតែអំបិលមួយក្ដាប់ប៉ុណ្ណោះ។

### ៤. សេចក្ដីថ្លែងការណ៍រៀបរាប់ទុក្ខសោកវេទនា ឥរិយាបថ និង ភាពគួរឲជឿជាក់បានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

នៅក្នុងសេចក្ដីថ្លែងការណ៍រៀបរាប់ទុក្ខសោកវេទនា លោកស្រី អោ រី បាននិយាយថា បន្ទាប់ពីចាកចេញភ្នំពេញនៅឆ្នាំ១៩៧៥ លោកស្រីបានបាត់បង់អ្វីៗគ្រប់យ៉ាង រួមទាំងគ្រួសារលោកស្រី ហើយក្លាយជាក្មេងកំព្រា។ លោកស្រីត្រូវបានបង្ខំឲផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀតរហូតមកដល់ខេត្តពោធិ៍សាត់ ដែលជាកន្លែងលោកស្រីត្រូវបានគេធ្វើទារុណកម្ម ពីព្រោះលោកស្រីនៅក្មេងពេកមិនអាចធ្វើការបានល្អ និងបានសុំអង្ករសម្រាប់អាហារ។ លោកស្រី អោ រី បានថ្លែងថា លោកស្រីទើបតែអាចរកឃើញបងស្រីម្នាក់ដែលនៅរស់មកទល់សព្វថ្ងៃនេះ ប៉ុន្តែ ដោយសារ *"របួសគាត់ គ្មានធ្វើអីកើតទេ ... គាត់គ្មានប្ដី គ្មានស៊ីអីទេ។"* លោកស្រី អោ រី បានសន្និដ្ឋានសេចក្ដីថ្លែងការណ៍ដោយទាមទារឲជួយរកយុត្តិធម៌ ដោយនិយាយថា *"ខ្ញុំក៏អកុសល ខ្ញុំក៏អាក្រក់ម្ល៉ោះ ជួបតែទុក្ខលំបាកវេទនា។ សូមឲលោកប្រធានជួយរកការខុសត្រូវឲខ្ញុំផង។"*

ដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយនឹងសំណួរ ដែលបានចោទសួរដោយពេញចិត្ត និង នៅតែអាចផ្ដល់សក្ខីកម្មបានធម្មតាទោះបីជាដល់ចំណុចឈឺចាប់បាត់បង់គ្រួសារក៏ដោយ។ លោកស្រីបានសារភាពដោយត្រង់ៗថា លោកស្រីមិនបានដឹងពីចម្លើយទាក់ទងនឹងស្ថានភាពរស់នៅនិងកំណើនប្រជាជន ក្នុងភ្នំពេញពេលខ្មែរក្រហមកំពុងវាយលុកកាន់តែខិតចូលភ្នំពេញ។ លោកស្រីបានពន្យល់ថា លោកស្រីនៅក្មេងពេកមិនបានតាមដានបញ្ហានេះទេ។

## គ. សក្ខីកម្ម ចៅ នី

ដើមបណ្ដឹងរដ្ឋប្បវេណី លោក ចៅ នី (TCCP 187) បានផ្ដល់សក្ខីកម្មពីបទពិសោធន៍រស់នៅក្នុងភ្នំពេញបន្ទាប់ពីគាត់បានចាកចេញពីកម្ពុជាក្រោមក្នុងឆ្នាំ១៩៧០ ហើយទៅធ្វើជាទាហានឲរដ្ឋាភិបាលគាំទ្រដោយអាមេរិកាំង។[6] គាត់មិនបានសម្រេចបំណងធ្វើជាទាហានទេ ដោយសារបងប្រុសគាត់បានហាមឃាត់។ គាត់បានស្នាក់នៅភ្នំពេញនិងមានវត្តមានពេលខ្មែរក្រហមបានវាយក្តោបក្ដាប់ភ្នំពេញ។ ដើមបណ្ដឹងរដ្ឋប្បវេណី

បានផ្តល់សក្ខីកម្មពីការចងចាំរបស់គាត់ ទាក់ទងនឹងការជម្លៀសចេញនិងបទពិសោធន៍គាត់ជាជនភៀសខ្លួនក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

## ១. ការជម្លៀសចេញពីភ្នំពេញ

លោក ចៅ នី ចាំបានថា នៅថ្ងៃ ១៧ មេសា ១៩៧៥ គាត់និងគ្រួសារបងប្រុសរបស់គាត់បានស្នាក់នៅផ្ទះរបស់បងប្រុសគាត់ ក្នុងខណៈអ្នកភ្នំពេញភាគច្រើនរួមទាំងទាហាន លន់ ណុល បានចេញមកអបអរសាទរជ័យជំនះរបស់ខ្មែរក្រហម។ បងប្រុស ចៅ នី បានធ្វើការឲធានាគារជាតិកម្ពុជានៅភ្នំពេញ។ បងប្រុសរបស់គាត់បានរៀបការ ហើយមានកូន៣៖ ចៅសួន ចៅយក្ស និង ចៅឡាបាំង។ លោក ចៅ នី បានថ្លែងថា ២ឬ៣ថ្ងៃក្រោយថ្ងៃ ១៧ មេសា ទាហានខ្មែរក្រហមមួយក្រុម បានប្រកាសឲប្រជាពលរដ្ឋត្រូវតែចាកចេញភ្នំពេញ។ តាមរយៈ លោក ចៅ នី ស្ថានការណ៍ពេលនោះ មានភាពរញ៉េរញ៉ៃណាស់ គាត់បានឮស្នូរគ្រាប់កាំភ្លើង និង ប្រជាពលរដ្ឋបានស្រែករកបងប្អូនសាច់ញាតិរសេះរសាយពេញទី។ គាត់បានអះអាងថាទាហានខ្មែរក្រហមប្រាប់អ្នករាល់គ្នាឲចាកចេញតែ៣ថ្ងៃទេ ពីព្រោះ ភ្នំពេញនឹងត្រូវរងការទម្លាក់គ្រាប់បែកពីទ័ពអាកាសអាមេរិកាំង។

គាត់និងបងប្រុសរបស់គាត់បានសម្រេចចិត្តទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ។ គាត់ចាំបានថាក្នុងខណៈគាត់ចាកចេញពីភ្នំពេញ មានអ្នកជម្ងឺ ចាស់ជរា មានទាំងសាកសព នៅតាមដងផ្លូវ ប៉ុន្តែអ្នកភៀសខ្លួនអាស្រ័យលើខ្លួនឯង ដោយគ្មានអ្នកណាអាចជួយអ្នកណាបានទេ។ គាត់បានសម្តែងមតិថា វាជាពេលវេលាដ៏លំបាកលំបិនមួយ ព្រោះវានៅរដូវភ្លៀង ហើយក្មេងៗហាលភ្លៀងហាលខ្យល់ គ្មានកន្លែងដេកពួនមានតែ វាលស្រែ។

## ២. ភូមិត្រពាំងសាប និង ការរើសអើងប្រឆាំងខ្មែរក្រោម

លោក ចៅ នី បានពរក្មួយគាត់ដោយរួមជាមួយអ្នកដំណើរជាច្រើនផ្សេងទៀតតាមផ្លូវជាតិលេខ២បានទៅដល់ភូមិត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។ គាត់បានសម្រេចចិត្តមិនធ្វើដំណើរបន្តទៅភូមិកំណើតរបស់គាត់ទៀតទេ បន្ទាប់ពីមានគេប្រាប់ថា ទាហានខ្មែរក្រហមនឹងសម្លាប់ខ្មែរកម្ពុជាក្រោមនៅតាមព្រំដែន។ ចាប់ពីនោះមក គាត់បានលាក់អត្តសញ្ញាណ រួមទាំងកន្លែងកំណើត និងប្តូរឈ្មោះគ្រួសារពី *"ចៅ"* ទៅ *"លន"*។ គាត់បានពន្យល់ថា ត្រកូល *"ចៅ"* អាចបង្ហាញអត្តសញ្ញាណគាត់ជាខ្មែរកម្ពុជាក្រោម ពីព្រោះប្រជាជននៅកម្ពុជាក្រោមបានជ្រើសរើសនាមត្រកូលពួកគេតាមទីកន្លែងដែលពួកគាត់ស្នាក់នៅ។ នាម *"ចៅ"* ត្រូវបានប្រើប្រាស់ដោយប្រជាជនមកពីស្រុកមាត់ជ្រូក។ គាត់ក៏បានប្រយ័ត្នប្រយែងរៀបចំសម្តី ដើម្បីបំភាន់អត្តសញ្ញាណរបស់គាត់។

យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ដំបូងឡើយ វាមិនទាន់មានការប្រកាសជាសាធារណៈពី កងឈ្លបប្រឆាំងនឹងខ្មែរក្រោមទេ ហើយគាត់ក៏នៅមិនទាន់ច្បាស់ថាតើខ្មែរក្រហមមានការរើសអើងនឹងខ្មែរក្រោមទេ ពីព្រោះខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនភាគតិចដោយស្មើភាពគ្នា ពេលដែលខ្មែរក្រហមនៅលាក់ពួនក្នុងព្រៃនៅឡើយ។ ប៉ុន្តែ បន្ទាប់ពីថ្ងៃរំដោះ១៩៧៩ គាត់អាចអះអាងថា តាមការពិត ខ្មែរក្រហមបានរើសអើងខ្មែរក្រោមពេលគាត់មកទួលស្លែងរកមើលសាច់ញាតិរបស់គាត់។ នៅទីនោះ គាត់បានឃើញពាក្យស្លោកខ្មែរក្រហមសរសេរនៅលើជញ្ជាំងថា *"កុំឆ្លើយថាឯងជាខ្មែរក្រោមដើម្បីរួចខ្លួន។"*

យោងតាមដើមបណ្តឹងរដ្ឋប្បវេណី នៅត្រពាំងសាប *"ប្រជាជនថ្មី"* ត្រូវបានគេរើសអើង ហើយ *"ស្ថានភាពនេះយើងមិនទ្រាំអាចនៅបាន។"* *"ប្រជាជនថ្មី"* ត្រូវបានចាត់ទុកជាពួកចក្រព័ទ្ធ ពួកមូលធននិយម ពួកសក្តិភូមិ និង ត្រូវបានចោទថា *"ធ្វើស្រែលើខ្នងរាស្ត្រ។"* ដូច្នេះ លោក ថៅ នី និងគ្រួសារ បានសម្រេចចិត្តត្រឡប់ទៅភ្នំពេញវិញនៅចុងឆ្នាំ១៩៧៥ ឬដើម១៩៧៦។ នៅតាមផ្លូវ មានមនុស្ស ស្លៀក ខ្មៅ ក្រមាវណ្ណាក និងទ្រនាប់ជើងកង់ឡានបានបញ្ឈប់ពួកគាត់ ហើយបង្គាប់ឲពួកគាត់ផ្លូវទិសដៅ។ លោក ថៅ នី ចាំបានថា *"គេហ្នឹងគេអត់ហ៊ានឲនៅយូរ។ ... ហើយខ្ញុំមិនដឹងទីតាំងទេ មិនដឹង ហើយមកដល់គោល ដៅត្រង់ណា ។"* ពេលពួកគាត់បានមកដល់ថ្នល់រថភ្លើង ទាហានខ្មែរក្រហម បានបង្ខំឲពួកគាត់ឡើងរថភ្លើង ដែលរួមមានអ្នកដំណើររាប់រយអ្នក។ លោក ថៅ នី បាននិយាយថា *"អារម្មណ៍ហ្នឹងមិនដឹងថាទៅកន្លែងស្លាប់ ឬមួយទៅកន្លែងណាទេ។ គ្រាន់តែថា បើបទបញ្ជាពួកឈ្លបហ្នឹង ខ្មែរក្រហមនោះ គឺគេបញ្ជាអ៊ីចឹងហើយ គឺត្រូវតែទៅ។ មិនមែនអ្វីមួយដែលយើងប្រឆាំងនឹងពាក្យគេទេ។ ទោះបីទៅកន្លែងនោះឲស្លាប់ក៏យើងត្រូវតែ ទៅដែរ។"*

## ៣. សហករណ៍ ចកធំ

អាស្រ័យតាម លោក ថៅ នី ប្រជាជនត្រូវបានបង្ខំឲរស់នៅក្នុងសហករណ៍ យោងតាមគោលនយោបាយបក្សកម្មុយនីស្តកម្ពុជា ហើយគ្មានអ្នកណាម្នាក់អាចគេចវេស ឬដេញដោលពីគោលនយោបាយនេះបានទេ។ លោក ថៅ នី និងអ្នកដំណើរផ្សេងទៀតត្រូវបានបង្គាប់ឲចុះពីរថភ្លើងនៅស្រុកម៉ងឬស្សីខេត្តបាត់ដំបង ហើយបន្តដំណើរតាមរទេះគោទៅដល់សហករណ៍ចកធំ។ នៅក្នុងសហករណ៍នេះ ប្រជាជនត្រូវបានប្រាប់ឲផ្តោតអារម្មណ៍ខិតខំធ្វើការលើផលស្រូវ ដើម្បីប្រមូលផលបាន២ឬ៣ដងក្នុងមួយឆ្នាំ ហើយ៣តោនក្នុង១ហិចតា។

តា ហឹយ ជាប្រធានសហករណ៍។ ដោយមិនដឹងពីមូលហេតុច្បាស់លាស់ យោងតាម លោក ថៅ នី តា ហឹយ ត្រូវបានគេដឹងថាជា *"ឃាតករសម្លាប់មនុស្សដោយញញឹម។"* លោក ថៅ នី មិនបានឃើញការសម្លាប់ដោយបុគ្គលនេះផ្ទាល់ទេ ប៉ុន្តែតាមការសង្កេត ប្រជាជនក្នុងភូមិនេះ មានចំនួនកាន់តែតិចទៅៗ។ ពេលដែលពួកគាត់ទើបមកដល់ដំបូង *"មានជាច្រើនគ្រួសារ"* និង ប្រជាជនរាប់រយនាក់ បានរស់នៅផ្ទះឬស្សី៣ជួរដែលសង់សម្រាប់ទទួល*"ប្រជាជនថ្មី"*។ *"មកចុងក្រោយកាន់តែខើចទៅៗ ឃើញតែផ្ទះចោលទេអត់ដឹងថាមនុស្សហ្នឹងទៅណាទេ។ ប៉ុន្តែផ្ទះអត់មានមនុស្សនៅទេ។"* លោក ថៅ នី មិនបានដឹងថាតើប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅកន្លែងផ្សេង ឬក៏ត្រូវបានសម្លាប់។

នៅចកធំ លោក ថៅ នី និងគ្រួសារបងប្អូនរបស់គាត់បានចាប់ផ្តើមទទួលអាហាររាល់ថ្ងៃ។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណី បបររាវគក្លូកមួយវែក ដែលពួកគេទទួលរៀងរាល់ពេលអាហារ មិនគ្រប់គ្រាន់ឡើយ ជាពិសេសបើប្រៀបធៀបទៅនឹងបន្ទុកការងារប្រចាំថ្ងៃ។ ដោយសារតែខ្វះខាតអាហារ ក្មួយប្រុស បងប្រុស និង បងថ្លៃរបស់គាត់ បានស្លាប់។ គាត់បានសម្តែងសេចក្តីទុក្ខសោកថា ក្រោយពីបានមកដល់ចកធំ ២ឬ៣ខែ ក្មួយប្រុសរបស់គាត់បានធ្លាក់ខ្លួនឈឺជាទំងន់រាករូសនិងស្រេកឃ្លាន។ គាត់ក៏ចាំបាន ពេលបងប្រុសរបស់គាត់អង្វរសុំស្ករត្នោតបន្តិចដើម្បីបរិភោគមុនពេលគាត់ស្លាប់ ប៉ុន្តែគ្រួសារគាត់មិនអាចបំពេញសំណូមពរសាមញ្ញនេះបានទេ។

ដោយស្រដៀងគ្នានឹងសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី អោ រី លោក ថៅ នី បាននិយាយថា មានតែ *"គ្រាប់អាចម៍ទន្សាយ"* ត្រូវបានប្រគល់ឲអ្នកជម្ងឺ មិនថាស្ថានភាពជម្ងឺធ្ងន់ធ្ងរយ៉ាងណាទេ។ ថ្នាំអាចម៍

ទន្សាយទាំងនេះ មិនមានប្រសិទ្ធភាពទេ។ ក្មួយគាត់ម្នាក់ បានស្លាប់ក្នុងរយៈពេល៣ម៉ោង បន្ទាប់ពីបានលេបគ្រាប់អាចម៍ទន្សាយ។ គាត់ក៏បានចងចាំថា បងប្រុសរបស់គាត់បានបដិសេធមិនទៅពេទ្យពេលគាត់ឈឺ *"បើអ្នកណាទៅដេកពេទ្យគេនោះ គឺអត់អាហារហើយ។ របបដែលយើងមាននៅក្នុងពេលដែលយើងនៅផ្ទះហ្នឹង ដែលពេលយើងទៅធ្វើការ តែយើងទៅដេកពេទ្យ គឺអត់មានរបបទៀតទេ។"*

ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីមានបទពិសោធន៍នៅត្រពាំងសាប ប្រជាជនមូលដ្ឋានត្រូវបានគេប្រព្រឹត្តផ្សេងគ្នាពីប្រជាជនថ្មី ឬ *"ប្រជាជន១៧មេសា"* នៅចកធំ។ ដូចដែលគាត់បានធ្វើនៅត្រពាំងសាប លោក ថៅ នី បានបន្តលាក់បាំងអត្តសញ្ញាណខ្មែរក្រោមរបស់គាត់នៅចកធំ។

### ៤. សេចក្តីថ្លែងការណ៍រៀបរាប់ទុក្ខសោកវេទនា ឥរិយាបថ និង ភាពគួរឲជឿជាក់បានរបស់ដើមដណ្តឹងរដ្ឋប្បវេណី

ពេលអង្គជំនុំជម្រះផ្តល់ឱកាសឲដើមបណ្តឹងរដ្ឋប្បវេណីសម្តែងសេចក្តីរងទុក្ខវេទនារបស់គាត់ពីរបបកម្ពុជាប្រជាធិបតេយ្យ លោក ថៅ នី បាននិយាយថា គាត់មានសំណួរ២សម្រាប់លោក **ខៀវ សំផន**៖ ១) ថាតើជនជាប់ចោទ **ខៀវ សំផន** បានជួប ថៅ សាយ ជាពូរបស់ ថៅ នី ក្រោយពី **ខៀវ សំផន** ត្រូវបានចោទថាបានសរសេរសំបុត្រឲ ថៅ សាយ ត្រឡប់មកភ្នំពេញវិញ និង ២) តើ ថៅ សាយ ស្លាប់នៅទីណា ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីអាចរកឃើញឆ្អឹងរបស់គាត់ ដែលនៅសល់យកមកធ្វើបុណ្យតាមសាសនា។ លោក ថៅ នី មិនបានទទួលចម្លើយទាំង២នេះទេ។ លោក **ខៀវ សំផន** បាននិយាយថា គាត់មិនឆ្លើយនឹង សំណួរទេ ហើយរងចាំរហូតដល់សេចក្តីបញ្ចប់នៃការដាក់បង្ហាញភ័ស្តុតាង មុនពេលឆ្លើយតបទៅនឹងសំណួរទាំងឡាយ។ (*មើល IV.ឃ.*) លោក ថៅ នី បានឆ្លើយតបដោយខកបំណងថា៖

> *ខ្ញុំសោកស្តាយណាស់ដែលសំណួរខ្ញុំ ចង់សួររកអ៊ំរបស់ខ្ញុំ មិនមែនថា ខៀវ សំផន អត់ស្គាល់ទេ។ ខៀវ សំផន គាត់ស្គាល់ ថៅ សៅ នេះច្បាស់ណាស់ គាត់ធ្លាប់ហូបបាយជាមួយគ្នាទៀត។ គាត់មិនដឹងថា សាកសព របស់គាត់ស្លាប់នៅទីណាទេ? គាត់មិនគួរបដិសេធទេ ... អ៊ីចឹងទុក្ខសោករបស់ខ្ញុំនៅដដែលហ្នឹង ទោះបីបានឡើងតុលាការយ៉ាងណា ក៏ខ្ញុំមិនអស់ចិត្តទេ។*

ក្នុងកំឡុងពេលធ្វើសក្ខីកម្មរបស់គាត់ លោក ថៅ នី បានត្រៀមជាស្រេចក្នុងការឆ្លើយសំណួរបានចំៗល្អប្រសើរ។ លោក ថៅ នី ចាប់មានអារម្មណ៍រំជួលចិត្តខ្លាំង ពេលគាត់និយាយពីភាពស្រេកឃ្លាន និងការស្លាប់របស់ក្មួយនិងបងប្រុសរបស់គាត់។ គាត់ ក៏មានសភាពខឹងសម្បាផងដែរ ពេលដែលគាត់មិនបានសមបំណងចំពោះ លោក ខៀវ សំផន ដែលមិនបានឆ្លើយនឹងសំណួររបស់គាត់ពីការស្លាប់នៃពូរបស់គាត់។

## III. បញ្ហាផ្នែកច្បាប់ និង នីតិវិធី

វាបានក្លាយជារឿងធម្មតាក្នុងពេលកាត់សេចក្តី ដែលភាគីតែងតែបានជំទាស់ទៅនឹងសំណួរដឹកមុខ និងសំណួរមិនពាក់ព័ន្ធ។ ជាកិច្ចបន្ថែម បញ្ហានីតិវិធីមួយត្រូវបានលើកឡើងនៅក្នុងម៉ោងចុងក្រោយនៃកិច្ច

ដំណើរការសវនាការក្នុងសប្តាហ៍នេះ ថាតើក្រុមការពារក្តីមានសិទ្ធិក្នុងការធ្វើបទបង្ហាញជាផ្លូវការលើសេចក្តីរៀបរាប់ពីទុក្ខសោកវេទនា។

## ក. ការប្រើប្រាស់សំណួរដឹកមុខនិងសំណួរសន្និដ្ឋាន

បែបបទនៃការប្រើប្រាស់សំណួរដឹកមុខនិងសំណួរសន្និដ្ឋាន ត្រូវបានជំទាស់តវ៉ាម្តងទៀត នាសប្តាហ៍នេះក្នុងតុលាការ។ ក្នុងខណៈមួយ ព្រះរាជអាជ្ញា វាំងសង់ វ៉ាយដ៍ ដេស្មាឯល បានសួរថាតើដើមបណ្តឹងរដ្ឋប្បវេណី មានចម្ងល់លើបញ្ហារបស់ខ្មែរក្រហមឲជម្លៀសចេញ ពីព្រោះ *"ថាតើលោកមានសួរខ្លួនឯងទេ"* ដែលថា លោក មាស សារ៉ាន់ បានបោះបង់ជីវិតអ្នកជម្ងឺក្នុងមន្ទីរពេទ្យដើម្បីជម្លៀសចេញ ហើយសង្គ្រោះជីវិតខ្លួនគាត់។[7] កញ្ញា ហ្គីសសេ បានជំទាស់នឹងសំណួររបស់ លោក វ៉ាយដ៍ ពីព្រោះវាមានពាក្យ *"ប្រសិនបើ"* ច្រើនពេក។ មេធាវីអន្តរជាតិរបស់លោក **នួន ជា** លោក អេនឌ្រូ អ៊ីនូហ្ស៊ី បានសំណូមពរថា ព្រះរាជអាជ្ញាសួរអ្វីដែលមានក្នុងគំនិតរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់លើកយកបញ្ហា *"ប្រៀបធៀបជាការសន្និដ្ឋាន។"* ប្រធានអង្គជំនុំបានយល់ស្របនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តី។

ក្រោយមក ពេលលោក អ៊ីនូហ្ស៊ី បានចោទសួរ លោក មាស សារ៉ាន់ ទាក់ទងនឹងស្ថានការណ៍គ្រោះថ្នាក់ក្នុងភ្នំពេញមុនចូលមកដល់ខែមេសា១៩៧៥ ហើយចាប់ផ្តើមសំណួរជាច្រើនលើកជាមួយ *"តើត្រឹមត្រូវដែរឬទេ?"* ឬ *"តើអ្នកយល់ស្របដែរឬទេ?"*[8] លោក វ៉ាយដ៍ ដេស្មាឯល បានជំទាស់នឹងការបន្តប្រើប្រាស់ឃ្លា *"ដូចជានាំមុខសាក្សីឲឆ្លើយ"*។[9] បន្ទាប់ពីចៅក្រមប្រឹក្សាគ្នា លោកប្រធានអង្គជំនុំ បានស្នើឲលោក អ៊ីនូហ្ស៊ី ជៀសវាងការដាក់សំណួរដឹកមុខទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សំណួរទាំងឡាយណាដែលតម្រូវឲធ្វើឧបមាណវិធី។ លោកប្រធានអង្គជំនុំជម្រះបាននិយាយថា សំណួរដឹកមុខតែងតែត្រូវបានហាមឃាត់តាំងពីដើមមកដោយសារតែសំណួរប្រភេទនេះស្នើឲដើមបណ្តឹងរដ្ឋប្បវេណីឬសាក្សីធ្វើការវាយតម្លៃសេចក្តីសន្និដ្ឋានដែលភាគីចង់បាន។ លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា សំណួរប្រភេទនេះ *"នីតិវិធីស៊ីវិលឡមិនអនុញ្ញាតឲធ្វើដូច្នេះទេ"* ហើយក៏ដូចជាតាមវិធានផ្ទៃក្នុងរបស់ **អ.វ.ត.ក.** ។ លោក អ៊ីនូហ្ស៊ី បានស្នើឲអង្គជំនុំជម្រះ បង្ហាញភស្តុតាងចេញពីយុត្តាធិការរបស់ប្រព័ន្ធស៊ីវិលឡណាមួយក្នុងពិភពលោកនេះដែលហាមឃាត់មិនឲប្រើសំណួរដឹកមុខដោយថ្លែងថា *"ចៅក្រម ឡាវែន៍ សួរសំណួរនាំមុខសហព្រះរាជអាជ្ញាសួរសំណួរបែបនេះ ដល់ដំណាក់ កាលនេះ។"* លោកប្រធានអង្គជំនុំជម្រះ បានកាត់ផ្តាច់មេក្រូគាត់ដោយអះអាងថា សេចក្តីសម្រេចត្រូវបានធ្វើរួចហើយ។

## ខ. ការសួរសំណួរមិនជាប់ពាក់ព័ន្ធ

ក្នុងកំឡុងពេលសួរដេញដោលលោក មាស សារ៉ាន់ លោកមេធាវី អ៊ីនូហ្ស៊ី បានដាក់សំណួរ មួយចំនួនដែលថា អង្គជំនុំជម្រះ *"និងមានពេលខ្លះ ដើមបណ្តឹងរដ្ឋប្បវេណីតែម្តង"* យល់ថាវាមិនជាប់ពាក់ព័ន្ធ។ ឧទាហរណ៍៖ លោកមេធាវីបានសាកសួរលោក មាស សារ៉ាន់ ថាតើស្ថានភាពលំបាកលំបិនក្នុងភ្នំពេញ *"វាបន្ថែមទម្ងន់ដែលធ្វើឲស្ថានភាពនោះ កាន់តែធ្ងន់តទៅទៀត ដែលនាំឲមានអំពើពុករលួយកាន់តែធ្ងន់មួយទៀតនៅក្នុងរបបរដ្ឋាភិបាល លន់ ណុល។"* ដើមបណ្តឹងរដ្ឋប្បវេណី បានបដិសេធមិនព្រមឆ្លើយនឹងសំណួរដោយនិយាយថា គាត់មកបំភ្លឺពីបទពិសោធន៍របស់គាត់ *"ខ្ញុំមិនធ្វើវិភាគលើអ្វីដែលថាលោកសួរហ្នឹងទេ។"*

ទោះបីជាមានការណែនាំពីសំណាក់ប្រធានអង្គជំនុំជម្រះ ឲគាត់ឆ្លើយតបនិងការធានាឲដើមបណ្ដឹងរដ្ឋប្បវេណី យល់ពីបំណងរបស់ លោក អ៊ីនូហ្ស៊ី ថាមិនមែនជាការរិះគន់ក្ដី លោក មាស សារ៉ាន់ នៅតែបដិសេធមិនឆ្លើយដោយថ្លែងថា *"ខ្ញុំមិនមានមកឆ្លើយក្នុងពេល ហ្នឹងរឿងនុ៎ងទេបាទ។ ខ្ញុំមកបង្ហាញ ថាតើខ្ញុំឃើញអីនៅពេលដែលមុនភ្នំពេញធ្លាក់។"*

លោក អ៊ីនូហ្ស៊ី បានបន្តសួរលោក មាស សារ៉ាន់ ពីសំណូមពររបស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឲសហរដ្ឋអាមេរិចលើកលែងសំណងក្នុងរបប លន់ ណុល។ ប្រធានអង្គជំនុំបានសម្រេចថាសំណួរនេះមិនមានការពាក់ព័ន្ធ។ មេធាវីការពារក្ដី ក៏បន្តសួរដើមបណ្ដឹងរដ្ឋប្បវេណី ហេតុអ្វីបានជាគាត់មានជំនឿម៉ុតមាំថា ការព្រមានរបស់ខ្មែរក្រហមពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងជាការ *"កុហក"*។ លោក អ៊ីនូហ្ស៊ី បានលើកឡើងពី សម្មតិកម្មមួយ ដែលចៅហ្វាយក្រុងម្នាក់ បានប្រាប់ឲប្រជាពលរដ្ឋជម្លៀសចេញពីផ្ទះសម្បែងដោយសារតែខ្លាចមានខ្យល់ព្យុះកំបុតត្បូង ដែលតាមពិតមិនដែលកើតឡើងនោះទេ។ បន្ទាប់មក លោក អ៊ីនូហ្ស៊ី បានសួរដើមបណ្ដឹងរដ្ឋប្បវេណី៖ *"តើលោកចាត់ទុកថា ការដែលខ្ញុំនិយាយនេះជាការកុហកដែរឬទេ?"* ប្រធានអង្គជំនុំបានកាត់សម្ដីលោកមេធាវី ហើយនិយាយថា វាជាសំណួរបែបឧបមាណវិធី។ លោក អ៊ីនូហ្ស៊ី បានឆ្លើយតបជាមួយនឹង សម្មតិកម្មទី២ថា អ្នកដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនេះ បានហាមឃាត់ មិនឲប្រើសំណួរដឹកមុខ ប៉ុន្តែសំណួរដឹកមុខត្រូវបានប្រើប្រាស់ជាហូរហែក្នុងបន្ទប់សវនាការនេះ។ លោកប្រធានអង្គជំនុំជម្រះបានកាត់ផ្ដាច់ លោក អ៊ីនូហ្ស៊ី ម្ដងទៀត ដោយថ្លែងថា បញ្ហានេះមិនត្រូវបានយកមកពិភាក្សាទៀតទេ ហើយប្រសិនបើ លោក អ៊ីនូហ្ស៊ី មិនមានសំណួរពាក់ព័ន្ធសម្រាប់សួរដើមបណ្ដឹងរដ្ឋប្បវេណីទៀតទេ ប្រធានអង្គជំនុំជម្រះនឹងប្រគល់វេទិកាឲភាគីផ្សេងទៀត។

ក្រោយមក លោក អ៊ីនូហ្ស៊ី បានសួរ លោក មាស សារ៉ាន់ ថាតើគាត់មានការបារម្ភណ៍ពីល្បឿននៃដំណើរការនីតិវិធី ហើយដែលថាតុលាការនេះ *"ខ្វះខាតថវិកា។"* លោកប្រធានអង្គជំនុំជម្រះបានរារាំងហើយបានស្នើឲ លោក អ៊ីនូហ្ស៊ី បន្តដាក់សំណួរផ្សេងទៀត។ បន្ទាប់មក លោក អ៊ីនូហ្ស៊ី បានលើកសំដៅលើអតីតប្រធានការិយាល័យរដ្ឋបាលនៃ **អ.វ.ត.ក.** ដែលបានលួច *"លុយរាប់ពាន់ដុល្លារ។"* លោកប្រធានអង្គជំនុំជម្រះបានព្រមានលោកមេធាវីថា ក្បាលមេក្រូរបស់គាត់នឹងត្រូវកាត់ផ្ដាច់ ប្រសិនបើគាត់នៅតែបន្តសួរសំណួរមិនពាក់ព័ន្ធ។ ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ បានរំឭក លោកមេធាវី អ៊ីនូហ្ស៊ី ថាដើមបណ្ដឹងរដ្ឋប្បវេណី *"គួរតែទទួលបាននូវការគោរព និងការប្រព្រឹត្តដោយមានមនុស្សធម៌"* ហើយប្រាប់គាត់ឲបញ្ចប់ការសួរដេញដោលប្រសិនបើគាត់មិនមានសំណួរដែលមាន *"ការគោរព"* ជាងនេះទេ។ លោកមេធាវី បានធានាពីសេចក្ដីគោរពដែលគាត់មានចំពោះ លោក មាស សារ៉ាន់ ដើម្បីជាការឆ្លើយតបទៅនឹងអ្វីដែលចៅក្រម ខាតវ៉ាយថ៍ បាននិយាយថា *"អ្វីដែលខ្ញុំធ្វើ គឺមិនមានលក្ខណៈមនុស្សធម៌។"* នៅក្នុងការប៉ុនប៉ងចុងក្រោយលើកប្រធានបទក្រៅមកនិយាយ លោក អ៊ីនូហ្ស៊ី បានសួរអំពីរបាយការណ៍សិទ្ធិមនុស្សថ្មីៗនេះ (Human Rights Watch) មកលើការសម្លាប់រៀបចំទុកជាមុន និង និទ្ទណ្ឌភាព ឬ ភាពគ្មានទោសពៃក្នុងប្រទេសកម្ពុជា។ លោកប្រធានអង្គជំនុំជម្រះបានកាត់សំដីម្ដងទៀត ហើយ មេធាវី អ៊ីនូហ្ស៊ី បានបញ្ចប់ការសួរដេញដោលត្រឹមនេះ។

## គ. សិទ្ធិរបស់មេធាវីការពារជនជាប់ចោទក្នុងការសម្តែងមតិលើសេចក្តីថ្លែងការណ៍រៀបរាប់ពីទុក្ខសោក វេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅពេលដែលអង្គជំនុំជម្រះបានផ្តល់ឱកាសឲភាគីទាំងអស់ បញ្ចេញមតិមកលើសេចក្តីថ្លែងការណ៍រៀបរាប់ទុក្ខវេទនារបស់លោក មាស សារ៉ាន់ លោក អាង ឧត្តម មេធាវីការពារជនជាប់ចោទ **អៀង សារី** បានថ្លែងថា គាត់សុំថ្លែងពីការសង្កេតឃើញជាទូទៅខ្លះៗអំពីដំណើរការនីតិវិធី ដែលគាត់សូមយកឱកាសនេះមកពិភាក្សា។ ប្រធានអង្គជំនុំជម្រះបានឆ្លើបតបថាវាមិនមែនជាពេលសមរម្យក្នុងការបញ្ចេញយោបល់ទេ។ ហេតុដូចនេះ លោក អាង ឧត្តម បានសូមបញ្ចេញយោបល់នាពេលក្រោយ។ ក្រោយៗមក នៅថ្ងៃសុក្រ ដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី បានថ្លែងថា គាត់ចង់សួរសំណួរដល់ជនជាប់ចោទ **ខៀវ សំផន** (*មើល II.គ.៤*)។ បញ្ហានេះបានធ្វើឲមានការពិភាក្សារវាងភាគីទាក់ទងនឹងបែបបទនៃការអនុញ្ញាតឲដើមបណ្តឹងរដ្ឋប្បវេណីនិយាយ ឬសួរសំណួរចំៗជាមួយជនជាប់ចោទដោយផ្ទាល់។ កញ្ញា ហ្គីសសេ បានទទូចថា ទោះបីជាវាមានសារៈសំខាន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការសម្តែងសេចក្តីរងទុក្ខវេទនា ក៏ដោយ វាមិនសាកសមសម្រាប់ពួកគាត់ក្នុងការនិយាយសំដៅទៅជនជាប់ចោទដោយផ្ទាល់។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ម៉ះដេវ ម៉ូហាន បានតវ៉ាថា វាគួរតែបានអនុញ្ញាតឲធ្វើដូច្នេះ ព្រោះវិធានផ្ទៃក្នុងមិនបានហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲនិយាយសំដៅទៅកាន់ជនជាប់ចោទទេ។ បន្ទាប់ពីមានការពិភាក្សាគ្នា អង្គជំនុំជម្រះបានបង្គាប់ឲ លោក ថៅ នី ដាក់សំណួររបស់គាត់តាមរយៈប្រធានអង្គជំនុំ ដែលជាអ្នកសម្រេចថាតើត្រូវសួរផ្ទាល់ទៅកាន់ **ខៀវ សំផន** ឬយ៉ាងណា។ ក្រោយពេល លោក ថៅ នី សួរសំណួររបស់គាត់ លោកប្រធានអង្គជំនុំជម្រះ បានដាក់សំណួរទៅកាន់ **ខៀវ សំផន** សូម្បីតែគាត់នៅតែរក្សាសិទ្ធិស្ងៀមស្ងាត់នៅឡើយ។

ក្រោយពេលដែល លោក ថៅ នី បញ្ចប់សក្ខីកម្មរបស់គាត់ ហើយរៀបរាប់ពីទុក្ខវេទនារបស់គាត់ អង្គជំនុំជម្រះ បានផ្តល់ឱកាសឲភាគីទាំងអស់ធ្វើការបញ្ចេញយោបល់។ ដោយហាក់ដូចជាធ្មើសចិត្តខ្លាំង កញ្ញា ហ្គីសសេ បានថ្លែងថា អ្វីដែលទើបតែកើតឡើងនេះ បាន *"រំលោភយ៉ាងធ្ងន់ធ្ងរទៅសិទ្ធិខាងការពារក្តី។"* កញ្ញាមេធាវី បានបន្តទៀតថា៖

> *ខ្ញុំសូមគូសបញ្ជាក់ថា ខ្ញុំឆ្ងល់ ហើយនិងរង្កៀសចិត្តមែនទែននូវដំណើរការស្តាប់សវនាការនេះ។ ពីព្រោះថា ខ្ញុំមិនមែនចំពោះដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវនិយាយតែពីការឈឺ ចាប់របស់ខ្លួនទេ ត្រូវនិយាយ ត្រូវនាំយកពីភស្តុតាងមកផង ហើយត្រូវគោរពតាម គោរពវិសាលភាពនៃការជម្រះសេចក្តីនេះផង។ ... វាខុសពីវិសាល ក្រៅពីវិសាលភាពនៃ សំណុំរឿង ០០២/១។ ... គឺថាដើមបណ្តឹងរដ្ឋប្បវេណីនេះគាត់និយាយចប់ហើយ អ៊ីចឹងខាងការ សិទ្ធិដែលសួរផ្តញ់ទៅគាត់នោះត្រូវបានរឹតត្បិត។*

លោកមេធាវី គង់ សំអុន បានថ្លែងថា វាមិនមានភស្តុតាងណាដែលអាចបញ្ជាក់ថា **ខៀវ សំផន** បានសម្លាប់ ឬ បង្កឲអ៊ំរបស់ លោក ថៅ នី ស្លាប់នោះទ ហើយក៏មិនមានភស្តុតាងណាដែលថា លោក **ខៀវ**

**សំផន** តាមពិតបានសរសេរទៅកាន់អ៊ំរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានឆ្លើយតបជំនួសឲអង្គជំនុំជម្រះថា៖

> *ខ្ញុំមិនយល់ទាល់តែសោះថាហេតុអីក៏មានការរំលោភសិទ្ធិលើភាគីការពារក្តី។ បើ សិនជា មើលទៅឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយទៅមានអង្គហេតុណាមួយ ដែលថាខាង ការពារក្តីនេះចង់ចោទសួរនោះ។ ក្នុងករណីនេះយើងអាចអនុញ្ញាត ឲខាងការពារក្តី សួរបាន។*

កញ្ញា ហ្គីសសេ បានដាក់ជាចម្ងល់ថា ប្រសិនបើកញ្ញាអាចមានឱកាសបន្តសួរ លោក ថៅ នី ដោយយល់ថា *"មិនដែលមាននិយាយលើកឡើងអំពីសំបុត្រដែលសរសេរដោយកូនក្តីរបស់ខ្ញុំ ឬក៏ផ្ញើជូនទៅពូរបស់គាត់។"* លោកប្រធានអង្គជំនុំជម្រះ និល ណុន បានរុញច្រានចោលការលើកឡើងនេះថា៖

> *អង្គជំនុំជម្រះមិនបន្តលើករណីនេះទៀតទេ។ ទី១ អង្គជំនុំជម្រះបានឲដើមបណ្តឹង រដ្ឋប្បវេណីវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់រួចហើយ។ បញ្ហាទី២ គឺជនជាប់ ចោទបានបង្ហាញជំហរច្បាស់លាស់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរួចហើយ។ ច្បាស់លាស់ហើយ។*

អង្គជំនុំជម្រះ មិនបានផ្តល់ឱកាសឲភាគីផ្សេងទៀតបញ្ចេញមតិលើសេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ លោក ថៅ នី នោះទេ។ ភ្លាមៗនោះដែរ លោកប្រធានចៅក្រមបានប្រកាសសម្រាកកិច្ចដំណើរសវនាការ ក្នុងខណៈ លោក អ៊ីនូហ្ស៊ី បានកំពុងឈរធ្វើបទដ្ឋានដើម្បីសុំការអនុញ្ញាតពីអង្គជំនុំជម្រះឲខ្លួនអាចមានមតិបន្ថែមទាំងទងបញ្ហានេះ ស្របពេលដែលអង្គចៅក្រមបានដើរចេញពីបន្ទប់សវនាការ។

## ឃ. សិទ្ធិរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតប និង សិទ្ធិតំណាងដោយមេធាវីរបស់ជនជាប់ចោទ

លោកប្រធានអង្គជំនុំជម្រះ បានណែនាំដល់ លោក **ខៀវ សំផន** ថាគាត់មានសិទ្ធិរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបនឹងសំណួររបស់ លោក ថៅ នី ហើយគាត់ក៏មានសិទ្ធិឆ្លើយតបនឹងសំណួរទាំងនោះ។ មេធាវី ហ្គីសសេ បានព្យាយាមរារាំងក្នុងការដាក់សំណួរទាំងនេះជាច្រើនលើក ប៉ុន្តែត្រូវបានលោកប្រធានអង្គជំនុំជម្រះកាត់ផ្តាច់មេក្រូ ដោយនិយាយថា *"យើងឲលោក **ខៀវ សំផន** ជាអ្នកសម្រេចចិត្ត ព្រោះយើងសួរទៅលោក **ខៀវ សំផន**។"* លោក អ៊ីនូហ្ស៊ី ក៏បានព្យាយាមកាត់ប្រសាសន៍ លោកប្រធានអង្គជំនុំជម្រះផងដែរ ដោយលើកឡើងថា គាត់ប្រឆាំងដាច់ខាតចំពោះការហាមប្រាមមកលើ មេធាវី ហ្គីសសេ មុនពេលដែលគាត់ត្រូវបានកាត់ផ្តាច់ដោយប្រធានអង្គជំនុំជម្រះ។ ទោះបីជាក្បាលមេក្រូមិនទាន់ដំណើរការក៏ដោយ ចៅក្រម ខាតវ៉ាយថ៍ បានខ្សឹបប្រាប់លោកប្រធានអង្គជំនុំជម្រះ ដែលអាចត្រូវបានស្តាប់ឮថា *"ឲដកគាត់ចេញទៅ...។"* ដោយមានការបង្ខិតបង្ខំពីអង្គជំនុំជម្រះ លោក **ខៀវ សំផន** បានថ្លែងថា៖

*សូមទោសលោកប្រធាន ខ្ញុំបានប្រគល់សិទ្ធិឲមេធាវីខ្ញុំ តំណាងឲខ្ញុំ។ ឯផ្ទាល់ខ្លួនខ្ញុំ ខ្ញុំបាននិយាយតាំងពីដើមទី ថា "ខ្ញុំបាទនឹងឆ្លើយជាយថាហេតុ នៅសំណួរ នៅពេលដែលចុងមានភស្តុតាងគ្រប់សព្វ គឺនៅចុងសវនាការនេះ។"*

ការបដិសេធរបស់អង្គជំនុំជម្រះម្តងហើយម្តងទៀតក្នុងការអនុញ្ញាតឲ មេធាវី ហ្គីសសេ ធ្វើបទដ្ឋានតំណាងឲកូនក្តីរបស់ខ្លួន ហើយ ការបង្គាប់ឲជនជាប់ចោទធ្វើមតិដោយមិនបានផ្តល់ឱកាសឲគាត់ប្រឹក្សាជាមួយមេធាវីរបស់ខ្លួន អាចត្រូវបានបកស្រាយបានថា វាជាការរំលោភលើសិទ្ធិជនជាប់ចោទ **ខៀវ សំផន** ក្នុងការការពារក្តីដោយមេធាវី។ *[មើល វិធានផ្ទៃក្នុង ២១. (១) (ឃ)]*

## IV. ការគ្រប់គ្រងសវនាការ

នាសប្តាហ៍នេះ តុលាការ អាចបញ្ចប់ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី៣រូប ក្នុងរយះពេល ២ថ្ងៃ។ ជាទូទៅ កិច្ចដំណើរការសវនាការ បានប្រព្រឹត្តទៅយ៉ាងរលូន រហូតទាល់តែមានបញ្ហាច្បាប់តានតឹងខ្លះៗ ត្រូវបានកើតឡើងនៅវេលាចុងក្រោយនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃសុក្រ។

### ក. វត្តមាន

លោក **អៀង សារី** ដែលបានបោះបង់សិទ្ធិមានវត្តមានក្នុងសវនាការដោយកំហិត[10] បានបន្តអវត្តមានពីកិច្ចដំណើរការសវនាការពេញមួយសប្តាហ៍ ព្រោះគាត់នៅតែកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារតែស្ថានភាពសុខភាពមិនអំណោយផល។ លោក **នួន ជា** ត្រូវបានអនុញ្ញាតឲសម្រាកនៅបន្ទប់តាមដានជាន់ក្រោមក្រោយពីវគ្គសវនាការទី១នៅថ្ងៃព្រហស្ប៍ បន្ទាប់ពីមានការអះអាងពីគ្រូពេទ្យប្រចាំការថា គាត់មិនសូវស្រួលខ្លួន។ នៅថ្ងៃសុក្រ លោក **នួន ជា** បានចូលរួមតាមដានក្នុងបន្ទប់សវនាការសម្រាប់វគ្គសវនាការពេលព្រឹក ហើយបានបន្តតាមដាននៅបន្ទប់តាមដានជាន់ក្រោមវិញនាពេលរសៀល។ លោក **ខៀវ សំផន** បានមានវត្តមានក្នុងបន្ទប់សវនាការនៅគ្រប់វគ្គសវនាការទាំងអស់ ក្នុងសប្តាហ៍នេះ។

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី៖*** ដើមបណ្តឹងរដ្ឋប្បវេណីចាប់ពី១០ទៅ២០នាក់បានចូលរួមតាមដានសវនាការជារៀងរាល់ថ្ងៃ ទាំងនៅក្នុងបន្ទប់សវនាការ ឬ ក្នុងសាលតាមដានសវនាការសាធារណះ។

***វត្តមានភាគី:*** ភាគីទាំងអស់ ត្រូវបានតំណាងឲបានត្រឹមត្រូវក្នុងកំឡុងពេលសប្តាហ៍នេះ។ យ៉ាងណាមិញ មេធាវីការពារអន្តរជាតិឲ **អៀង សារី** លោក ម៉ៃឃើល កាណាវ៉ាស បានអវត្តមាន។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ ក៏បានអវត្តមានផងដែរ ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក វ៉ែន ពៅ ត្រូវបានចាត់តាំងឲជំនួសតួនាទី លោក ពេជ អង្គ។ ក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះ បានទទួលស្គាល់ លោក ម៉ះដេវ ម៉ូហាន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ ហើយ លោក អ៊ុក វីរះ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ។

*វត្តមានសាធារណៈ៖*

| កាលបរិច្ឆេទ | សវនាការនាពេលព្រឹក | សវនាការនាពេលរសៀល |
|---|---|---|
| ថ្ងៃព្រហស្បតិ៍ ២២/១១/១២ | ▪ សិស្សានុសិស្ស ២៥០ នាក់ មកពីវិទ្យាល័យ ពង្សរូ ខេត្តព្រៃវែង<br>▪ អ្នកសង្កេតការបរទេស ១២ នាក់ | ▪ សិស្សានុសិស្ស ១៥០ នាក់ មកពីវិទ្យាល័យ កោះអណ្តែត ខេត្តតាកែវ<br>▪ អ្នកសង្កេតការបរទេស ៥ នាក់ |
| ថ្ងៃសុក្រ ២៣/១១/១២ | ▪ សិស្សានុសិស្ស ៣០០ នាក់ មកពីមហាវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង<br>▪ អ្នកសង្កេតការបរទេស ១២ នាក់<br>▪ ព្រះសង្ឃ ១ អង្គ | ▪ សិស្សានុសិស្ស ២៣០ នាក់ មកពីអង្គការកុមារញញឹម<br>▪ អ្នកសង្កេតការបរទេស ៤ នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

តុលាការបានធ្វើសវនាការចាប់ពីថ្ងៃព្រហស្ប៍ដល់ថ្ងៃសុក្រ ហើយបានសម្រេចក្នុងការស្តាប់សក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី៣រូប។ ម៉្យាងវិញទៀត កិច្ចដំណើរការសវនាការបានចាប់ផ្តើមយឺត ជាង២០នាទី នៅថ្ងៃព្រហស្ប៍ ដោយសារតែបញ្ហាបច្ចេកទេសសម្លេង និង បញ្ចប់មុនម៉ោងកំណត់ នៅថ្ងៃសុក្រ ក្រោយពេល បានបញ្ចប់សក្ខីកម្មរបស់ លោក ថៅ នី។

## គ. ឥរិយាបថក្នុងបន្ទប់សវនាការ

កិច្ចដំណើរការសវនាការនៅថ្ងៃព្រហស្ប៍មានសភាពស្ងប់ស្ងាត់ ដោយសារប្រធានអង្គជំនុំជម្រះត្រូវ បានសម្គាល់ឃើញថាមានការអត់ធ្មត់ច្រើន ទោះបីជា លោក អ៊ីនូហ្ស៊ី បានប៉ុនប៉ងម្តងហើយម្តងទៀតក្នុង ការដាក់សំណួរដែលត្រូវបានសម្រេចថាមិនជាប់ពាក់ព័ន្ធ។ *មើល (IV.ខ)* យ៉ាងណាក្តី ភាពល្អក់កករវាង ភាគីទាំងពីរបានកើតឡើងវិញនៅថ្ងៃសុក្រ។ ពេលលោកស្រីមេធាវី ទី ស្រ៊ីនណា បានដាក់សំណួរថាហេតុអ្វី បានជា ម្តាយរបស់ លោកស្រី អោ រី ត្រូវបានគេឃុំខ្លួន (មើល II.ខ.៣) លោកប្រធានអង្គជំនុំជម្រះ និល ណុន មិនអនុញ្ញាតឲដាក់សំណួរនេះទេ ដែលស្របនឹងការជំទាស់របស់ លោក អាង ឧត្តម។ លោកប្រធាន បានលើកហេតុផលថា ដើមបណ្តឹងរដ្ឋប្បវេណីបាននឹងកំពុងធ្វើសក្ខីកម្មពីគោលនយោបាយជម្លៀសប្រជាជន *"តាំងពីដើមដំណាក់កាលធ្វើដំណើរការវិវត្ត នៃការជម្លៀស និងទៅដល់ភ្លាម ទៅដល់គោលដៅភ្លាម"* ហើយសក្ខីកម្ម លោកស្រី អោ រី មិនបានគ្របដណ្តប់លើព្រឹត្តការណ៍ដែលបានកើតឡើង ៣ ឬ ៤ ឆ្នាំក្រោយ មកទេ។ ត្រង់ចំនុចនេះ លោក អ៊ីនូហ្ស៊ី បានចោទសួរថា *"តើវាជាការត្រឹមត្រូវដែរឬទេ ខ្ញុំស្តាប់ទៅវាដូចជា ការបន្ទោសឬក៏ជាការពន្លឿន -- តើលោកប្រធានមិនអីទេឬ? លោកហាក់បីដូចជានៅមិនសូវស្រួល--។"* ដោយសម្តែងចេញអាការៈមិនសប្បាយចិត្តនឹងសំណួរនេះ លោកប្រធានបានឆ្លើយតបវិញ៖ *"លោកមានបញ្ហា អីទេ? យើងដោះស្រាយលើសេចក្តីជំទាស់ កត់សម្គាល់របស់មេធាវីការពារក្តីលោក អៀង សារី ... យើងគិតថាលោកមេធាវីមិនមានគុណភាពវិនិច្ឆ័យយើងថា យើងខុស ឬក៏យើងត្រូវនោះទេ។"*

## ឃ. បញ្ហាបកប្រែ និង បច្ចេកទេស

នាសប្តាហ៍នេះ ការបកប្រែបានប្រព្រឹត្តទៅដោយរលូន ដោយមិនមានបញ្ហាអ្វីគួរឲកត់សម្គាល់ទេ។ យ៉ាងណាមិញ បញ្ហាបច្ចេកទេស បានកើតឡើងក្នុងប្រព័ន្ធសោតទស្សជាញឹកញាប់ បណ្តាលឲមានការពន្យារពេលចាប់ផ្តើមកិច្ចដំណើរការសវនាការអស់រយៈពេល២០នាទីនៅថ្ងៃ ព្រហស្ប៍ ហើយបង្អាក់កិច្ចដំណើរការសវនាការ២ឬ៣នាទី នៅព្រឹកថ្ងៃសុក្រ។

## ង. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ព្រហស្បតិ៍ ២២/១១/១២ | ៩:២៥ | ១០:៤៧-១១:០៦ | ១២:០៧-១៣:៣៤ | ១៤:៣៩-១៥:០៥ | ១៦:០៥ | ៤ ម៉ោង និង ២៨ នាទី |
| សុក្រ ២៣/១១/១២ | ៩:០១ | ១០:៣៦-១១:០០ | ១២:០៦-១៣:៣២ | ១៤:៣៣ | - | ៣ ម៉ោង និង ៤២ នាទី |
| រយៈពេលសវនាការជាមធ្យម | | | | ៤ ម៉ោង និង ៥ នាទី | | |
| រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ | | | | ៨ ម៉ោង និង ១០ នាទី | | |
| ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍ នៃសវនាការ | | | | ៥៧៣ ម៉ោង និង ២៨ នាទី | | |
| រយៈពេលសវនាការចំនួន១៣០ថ្ងៃ ក្នុងអំឡុងពេល ៤០ សប្តាហ៍ | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"* (Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Faith Suzzette Delos Reyes, Daniel Mattes, Noyel Ry, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] For Meas Saran's initial testimony, *see* CASE 002 KRT TRIAL MONITOR. Issue No. 43, Hearing on Evidence Week 38 (12-14 November 2012).

[2] Meas Saran was examined in the following order: international Civil Party Lawyer Christine Martineau (continuing her questioning from the prior week); international Prosecutor Vincent de Wilde d'Estmael; national Prosecutor Chan Dararasmay; Judge Jean-Marc Lavergne; international Counsel for Nuon Chea, Andrew Ianuzzi. Civil Party was then offered the opportunity to make his statement of suffering.

[3] In response to questions put to him by the Office of the Co-Prosecutors on 30 January 2012, Nuon Chea said that the Central Committee decided to evacuate all the inhabitants of Phnom Penh, including all of the city's injured or ill, who they failed to fully "think about" in the dire situation of the time. The transcript from this date is document number E1/35.1

[4] The Civil Party was questioned in the following order: Civil Party Lawyer Ty Srinna; Mr. Son Arun, national counsel for Nuon Chea; and Mr. Andrew Ianuzzi, international counsel for Nuon Chea. Mr. Ang Udom, national counsel for Ieng Sary, sought only to clarify the marital status of the Civil Party, saying that, in a March 1999 family book, Or Ry wrote that she was married, however, her Civil Party application said she is single. Or Ry said, "I don't know what happened with that. I got married after the Khmer Rouge regime." The Khieu Samphan defense team had no questions for Or Ry

[5] Thong Domrey Village is in Takeo Province.

[6] Chau Ny was questioned in the following order: national Civil Party Lawyer Kong Phallack, international Civil Party lawyer Mahdev Mohan, international Prosecutor Tarik Abdulhak, Judge Jean-Marc Lavergne. None of the defense teams had questions for the Civil Party.

[7] Only earlier this month, Michael Karnavas said that Vincent de Wilde d'Estmael utilizes leading questions excessively. See CASE 002 KRT TRIAL MONITOR. Issue No. 42, Hearing on Evidence Week 37 (5-8 November 2012). 8.

[8] Meas Saran, de Wilde d'Estmael, and the President had also asked Ianuzzi to shorten and rephrase an earlier question that appeared to intone a certain response regarding the possible link between the civil war and Phnom Penh's food shortages. However, even as Ianuzzi willingly edited his question, Judge Silvia Cartwright intervened to deliver a terse restatement of what the others had already asked of him: "Your questions are being asked too fast and are too complicated for the translation for the Civil Party."

[9] Examples of Ianuzzi's questions include: "Would you agree, as some have said, that the population of the city had more than doubled by April 1975? Are you able to make that assessment?" or "Is it fair to say that prior to your departure to Sisophon, by 1973, the city was already facing serious healthcare problems in terms of the availability of supplies at the hospitals and things like that?"

[10] In accordance with Internal Rule 81 (1) and Articles 14 (1) and 14 (3) (d) of the International Covenant for Civil and Political Rights, Accused Ieng Sary issued a Limited Waiver, agreeing to waive his direct presence in the courtroom for 1 Civil Party and 7 witnesses. He explicitly stated that he is not waiving his right to be present for other witnesses. *See* Ieng Sary. "Limited Waiver" (18 September 2012). E229. Due to his extended stay in the hospital, he subsequently issued another Limited Waiver for 11 additional witnesses and 7 Civil Parties. *See* Ieng Sary. "Limited Waiver" (1 October 2012). E237.